លទ្ធផលនៃ
ការអនុវត្តថវិកាឆមាសទី១ និង
ការវាយតម្លៃការអនុវត្ត
ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់
ការគ្រប់គ្រង ឆ្នាំ២០២២

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

របាយការណ៍
ស្តីពី
លទ្ធផលនៃការអនុវត្តថវិកាឆមាសទី ១ និងការវាយតម្លៃការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២២

១-សេចក្តីផ្តើម

ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២២ (ច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០២២) ត្រូវបានអនុវត្តអស់រយៈពេលជាង ៦ ខែ នៃឆ្នាំ ២០២២ ដើម្បីសម្រេចលទ្ធផលសំខាន់ៗដែលជាអាទិភាពគោលនយោបាយ និង វិធានការកែទម្រង់ជាក់ស្តែងនានារបស់រាជរដ្ឋាភិបាល ឆ្លើយតបទៅនឹងសំណូមពរ សេចក្តីត្រូវការ និងការរំពឹងទុករបស់ប្រជាជនកម្ពុជា នៅក្នុងដំណាក់កាលនៃសុខសន្តិភាព និងការអភិវឌ្ឍ។ ដូចនេះ អនុលោមតាមច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និងដើម្បីជាមូលដ្ឋានព័ត៌មានដែលមានបច្ចុប្បន្នភាព និងច្បាស់លាស់សម្រាប់រាជរដ្ឋាភិបាលបន្តដឹកនាំវិស័យសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈប្រកបដោយប្រសិទ្ធភាពខ្ពស់ជាពិសេស ក្នុងបរិការណ៍ដែលពិភពលោក ក៏ដូចជាកម្ពុជាកំពុងទទួលរងផលប៉ះពាល់ពីវិបត្តិជំងឺកូវីដ-១៩ នៅឡើយ ព្រមទាំងសង្គ្រាមនៅអ៊ុយក្រែន ជាពិសេសបញ្ហាអតិផរណា, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានរៀបចំរបាយការណ៍ស្តីពីការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២២ នៅក្នុងឆមាសទី ១ ដោយពិនិត្យ និងវាយតម្លៃអំពីស្ថានភាពម៉ាក្រូសេដ្ឋកិច្ច និងលទ្ធផលនៃការអនុវត្តថវិកាក្នុងឆមាសទី១ ព្រមទាំងការវាយតម្លៃការអនុវត្តថវិការហូតដល់ដំណាច់ឆ្នាំ ២០២២ ដោយកំណត់នូវបញ្ហាប្រឈម ក៏ដូចជាដាក់ចេញនូវចំណាត់ការ និងសំណើវិធានការផ្សេងៗ ដើម្បីធានាឱ្យការអនុវត្តច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០២២ ទទួលបានជោគជ័យ និងប្រកបដោយប្រសិទ្ធភាពខ្ពស់។

២-គោលនយោបាយ និងក្របខ័ណ្ឌថវិកានៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២២ ដែលត្រូវបានដាក់ចេញ

២.១-អាទិភាពគោលនយោបាយដែលត្រូវបានដាក់ចេញនៅក្នុងច្បាប់ហិរញ្ញវត្ថុ ២០២២

ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២២ ត្រូវបានរៀបចំឡើងនៅក្នុងបរិការណ៍ដែលកម្ពុជាកំពុងស្ថិតនៅកណ្តាលនៃវិបត្តិជំងឺកូវីដ-១៩ បន្ទាប់ពី **ព្រឹត្តិការណ៍សហគមន៍ ២០ កុម្ភៈ ២០២១** និង ការបន្តរីករាលដាលនៃមេរោគកូរ៉ូណាបំប្លែងថ្មីជាបន្តបន្ទាប់ ដែលបានបង្កឱ្យមានផលប៉ះពាល់អវិជ្ជមានធ្ងន់ធ្ងរ ដល់សុខភាព សង្គម សេដ្ឋកិច្ច និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ព្រមទាំងកំពុងដាក់សម្ពាធកាន់តែធ្ងន់មកលើថវិកាជាតិ។

ឈរលើមូលដ្ឋានខាងលើ ថវិកាឆ្នាំ ២០២២ ត្រូវបានគិតគូរ និងរៀបចំឡើង ដើម្បីតម្រង់ធនធានដើម្បីបន្តប្រយុទ្ធការពារអាយុជីវិតប្រជាជន ក្សាលំនឹងសង្គម-សេដ្ឋកិច្ច និងជីវភាពរស់នៅរបស់ប្រជាជន ព្រមទាំងដើម្បីស្តារ និងជំរុញកំណើនសេដ្ឋកិច្ចឡើងវិញ ទន្ទឹមនឹងការបន្តនិរន្តរភាពនៃប្រតិបត្តិការរបស់រដ្ឋ និងការបន្តជំរុញការអនុវត្តកម្មវិធីកែទម្រង់សំខាន់ៗរបស់រាជរដ្ឋាភិបាល ក្នុងទិសដៅឈានទៅសម្រេចឱ្យ

បានជាអតិបរមានូវ គោលដៅជាយុទ្ធសាស្ត្រទាំង ៤ ដូចមានចែងក្នុង "**យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី ៤ ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព : កសាងមូលដ្ឋានឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជា ឆ្នាំ ២០៥០**" ដែលជារបៀបវារៈគោលនយោបាយសង្គម-សេដ្ឋកិច្ច នៃ**កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី ៦ នៃរដ្ឋសភា** ដែលរួមមានដូចខាងក្រោម៖

ទី១. ធានាឱ្យបានកំណើនសេដ្ឋកិច្ចខ្ពស់ឡើងវិញ ប្រកបដោយចីរភាព និងធន់នឹងវិបត្តិ តាមរយៈការធ្វើពិពិធកម្មមូលដ្ឋានសេដ្ឋកិច្ចឱ្យបានទូលំទូលាយ និងមានភាពប្រកួតប្រជែង ជាមួយនឹងការថែរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច តាមរយៈការគ្រប់គ្រងអត្រាអតិផរណាឱ្យនៅទាប ការធានាស្ថិរភាពអត្រាប្តូរប្រាក់ ការខិតខំបង្កើនទុនបម្រុងជាប្រចាំ និងការគ្រប់គ្រងបំណុលសាធារណៈដោយគត់មត់។

ទី២. បង្កើតការងារឱ្យបានកាន់តែច្រើន ទាំងបរិមាណ និងគុណភាព ជូនដល់ប្រជាជនកម្ពុជា ពិសេសសម្រាប់ស្រទាប់យុវជន តាមរយៈការផ្តល់ជំនាញ ព័ត៌មានទីផ្សារការងារ ការកែលម្អ លក្ខខណ្ឌការងារ ការលើកកម្ពស់សកម្មភាពធុរកិច្ច និងការជំរុញការវិនិយោគ ទាំងក្នុង និងក្រៅប្រទេស។

ទី៣. សម្រេចឱ្យបាននូវគោលដៅនៃការកាត់បន្ថយភាពក្រីក្រ ដោយផ្តោតលើការលើកកម្ពស់ការចូលរួមក្នុងយន្តការទីផ្សារ ការអនុវត្តគោលនយោបាយគាំពារសង្គម ការកាត់បន្ថយបន្ទុកជីវភាពរស់នៅ និងការផ្តល់សេវាសាធារណៈប្រកបដោយគុណភាព និងការកាត់បន្ថយគម្លាតសង្គម។

ទី៤. បន្តពង្រឹងសមត្ថភាព និងអភិបាលកិច្ចនៃស្ថាប័នរដ្ឋ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីធានាឱ្យបាននូវប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពនៃសេវាសាធារណៈ សំដៅបម្រើប្រជាជនឱ្យបានកាន់តែប្រសើរឡើង ក៏ដូចជាលើកកម្ពស់បរិយាកាសធុរកិច្ច និងបរិស្ថានអំណោយផលសម្រាប់ការវិនិយោគ។

យ៉ាងណាមិញ នៅក្នុងបរិការណ៍នៃវិបត្តិជំងឺកូវីដ-១៩ ក្នុងឆ្នាំ ២០២១, **ថវិកាឆ្នាំ ២០២២ ត្រូវបានផ្តល់អាទិភាពខ្ពស់បំផុតដល់ចំណាយចាំបាច់ទាំងឡាយសំដៅទប់ទល់ការរាតត្បាត និងកាត់បន្ថយផលប៉ះពាល់ពីជំងឺកូវីដ-១៩** ទន្ទឹមនឹងការបន្តផ្តោតការយកចិត្តទុកដាក់លើ **វិស័យអាទិភាព ៤ គឺ មនុស្ស ផ្លូវ ភ្លើង** និង **ទឹក** ព្រមទាំងកិច្ចការមួយចំនួនទៀត ដែលឆ្លើយតបនឹងតម្រូវការអភិវឌ្ឍកម្ពុជានៅក្នុងដំណាក់កាលថ្មី ដែលមានដូចខាងក្រោម៖

ទី១. ការអភិវឌ្ឍធនធានមនុស្ស ដោយនឹងបន្តផ្តោតលើការពង្រឹងគុណភាពវិស័យអប់រំ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា និងការបណ្តុះបណ្តាលជំនាញបច្ចេកទេស ការលើកកម្ពស់សេវាសុខភាពសាធារណៈ និងការគាំពារសង្គម។

ទី២. ការបន្តកែលម្អប្រព័ន្ធឡូជីស្ទីក ការលើកកម្ពស់ការតភ្ជាប់ផ្នែកដឹកជញ្ជូន ថាមពល និងឌីជីថល និងការអភិវឌ្ឍប្រភពកំណើនសេដ្ឋកិច្ចគន្លឹះ និងថ្មីៗ ព្រមទាំងការរៀបចំខ្លួនសម្រាប់សេដ្ឋកិច្ចឌីជីថល និងបដិវត្តន៍ឧស្សាហកម្មទី៤។

ទី៣. ការពង្រឹងការប្រកួតប្រជែង និងការលើកស្ទួយសហគ្រាសធុនតូច និងមធ្យម ព្រមទាំងសហគ្រិនភាព ដើម្បីបង្កើនផលិតភាព និងប្រសិទ្ធភាពសេដ្ឋកិច្ច។

ទី៤. ការលើកស្ទួយវិស័យកសិកម្ម និងការអភិវឌ្ឍជនបទ ការគ្រប់គ្រងនគរូបនីយកម្ម និង ការគ្រប់គ្រងធនធានធម្មជាតិ ព្រមទាំងការធានាចីរភាពបរិស្ថាន ក្នុងគោលដៅអភិវឌ្ឍប្រកបដោយចីរភាពនៅកម្ពុជា។

២.២-ក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចដែលត្រូវបានដាក់ចេញនៅក្នុងច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០២២

ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២២ ត្រូវបានរៀបចំឡើងដោយឈរលើមូលដ្ឋាននៃក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចសម្រាប់ឆ្នាំ ២០២២ ដែលមានសូចនាករសំខាន់ៗ ដូចខាងក្រោម៖

• កំណើនសេដ្ឋកិច្ចនៅឆ្នាំ ២០២២ ស្ថិតក្នុងរង្វង់អត្រា ៤,៨% ដែលធ្វើឱ្យផលិតផលក្នុងស្រុកសរុប (ផសស) ថ្លៃបច្ចុប្បន្ន ស្ថិតក្នុងរង្វង់ ១២៤ ១៦២ ប៊ីលានរៀល ឬសមមូលនឹងប្រមាណ ៣០ ៥៤៤ លានដុល្លារអាម៉េរិក ស្របពេលដែល ផសស សម្រាប់មនុស្សម្នាក់ ត្រូវបានរំពឹងថានឹងកើនឡើងដល់១ ៨៤២ ដុល្លារអាម៉េរិក;

• អតិផរណានឹងត្រូវរក្សាឱ្យស្ថិតក្នុងរង្វង់ ២,៨%;

• អត្រាប្តូរប្រាក់រៀល-ដុល្លារអាម៉េរិកនឹងត្រូវរក្សាឱ្យស្ថិតក្នុងរង្វង់ ៤ ០៦៥ រៀល ក្នុង ១ ដុល្លារអាម៉េរិក;

• ឱនភាពគណនីចរន្ត (រួមបញ្ចូលបង្វែរ) ត្រូវបានប៉ាន់ប្រមាណថានឹងរួមតូចក្នុងរង្វង់ ១៣,១% នៃ ផសស ក្នុងឆ្នាំ ២០២២ ដោយសារការរំពឹងនៃការងើបឡើងវិញសន្សឹមៗនូវការនាំចេញ និងវិស័យទេសចរណ៍។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមគូសបញ្ជាក់ថា អាទិភាពគោលនយោបាយ ក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច និងក្របខ័ណ្ឌថវិកា ដែលបានដាក់ចេញក្នុងច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០២២ គឺបានគិតគូរនៅពាក់កណ្តាលឆ្នាំ ២០២១ ដើម្បីជំរុញអនុវត្តយុទ្ធសាស្ត្រស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា ក្នុងការរស់នៅជាមួយនឹងកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី ក៏ដូចជាការអនុវត្តវិធានការអន្តរាគមន៍សមស្រប និងទាន់ពេលក្នុងគោលបំណងរក្សាលំនឹងសង្គម-សេដ្ឋកិច្ច និងជំរុញកំណើនឡើងវិញ។

២.៣-ក្របខ័ណ្ឌគោលនយោបាយថវិកាឆ្នាំ ២០២២ ដែលត្រូវបានដាក់ចេញ

ក្នុងគោលបំណងដើម្បីសម្រេចបានតាមគោលដៅខាងអាទិភាពគោលនយោបាយ និងគោលដៅខាងផ្នែកម៉ាក្រូសេដ្ឋកិច្ច ដូចបានគូសបញ្ជាក់ខាងលើ រាជរដ្ឋាភិបាលបានដាក់ចេញនូវក្របខ័ណ្ឌថវិកាឆ្នាំ ២០២២ ដូចខាងក្រោម៖

តារាងទី ១៖ តារាងតុល្យភាពថវិការដ្ឋ (ច្បាប់ឆ្នាំ ២០២២)

សូចនាករ	២០២០	២០២១		២០២២	
	អនុវត្ត	ច្បាប់	អនុវត្ត	ច្បាប់	
ផសស (លានរៀល)	១០៩ ០៦១ ៩០៧	១១០ ៥០៥ ៩១៦		១២៤ ១៦១ ៦២៥ (*)	១២០ ៣១២ ៤៧៧ (**)
ចំណូលក្នុងប្រទេស (%ផសស)	២១,៨១%	១៩,៨១%	២០,៦៥%	២០,៦១%	២១,២៧%
- ចំណូលចរន្ត (%ផសស)	២១,៦៤%	*១៩,២១%*	*២០,៦០%*	១៩,៥៦%	២០,១៩%
ចំណាយសរុបថវិការដ្ឋ (%ផសស)	២៨,៨០%	២៨,៩៧%	៣១,០៣%	២៧,៩៥%	២៨,៨៥%
- ចំណាយចរន្ត (%ផសស)	១៧,២៥%	*១៦,៩៧%*	*១៩,៥៣%*	១៦,៧៩%	១៧,៣៣%
អតិរេកចរន្ត (%ផសស)	៤,៣៩%	២,២៤%	១,០៧%	២,៧៧%	២,៨៦%
ឱនភាពសរុប (%ផសស)	-៧,០០%	-៩,៥៦%	-១០,៣៧%	-៧,៣៤%	-៧,៥៥%

សេចក្តីបញ្ជាក់÷

-(*) ផសស តាមថ្លៃបច្ចុប្បន្ន ដែលបានព្យាករណ៍នៅក្នុងឆ្នាំ ២០២១ សម្រាប់ការរៀបចំច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០២២

-(**) ផសស តាមថ្លៃបច្ចុប្បន្ន ផ្អែកលើក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈឆ្នាំ ២០២២ (ពាក់កណ្តាលឆ្នាំ ២០២២)

តាម ផសស គិតជាទឹកប្រាក់តាមថ្លៃបច្ចុប្បន្នដែលបានព្យាករណ៍នៅក្នុងឆ្នាំ ២០២១ សម្រាប់ការរៀបចំច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០២២ ចំណូលក្នុងប្រទេសថវិការដ្ឋ ត្រូវបានគ្រោងចំនួន ២៥ ៥៩៤ ៣៦៦ លានរៀល ត្រូវជា

២០,៦១% នៃ ផសស ដែលមានការកើនឡើង ១៩,៣% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០២១។ ក្នុងបរិការណ៍នៃវិបត្តិជំងឺកូវីដ-១៩ នៅ៣ក់កណ្តាលឆ្នាំ ២០២១ ក្របខ័ណ្ឌថវិកាឆ្នាំ ២០២២ មានគោលដៅបង្កើនចំណូលចរន្តថវិការដ្ឋឱ្យបានស្មើនឹង ១៩,៥៦% នៃ ផសស ដែលមានការកើនឡើងចំនួន ០,៣៥ ពិន្ទុភាគរយ នៃ ផសស ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០២១ ពេលគឺនឹងសម្រេចបានខ្ពស់ជាងគោលដៅនៃការប្រមូលចំណូលចរន្តថវិការដ្ឋ ដែលត្រូវបានកំណត់ឱ្យកើនជាមធ្យម ០,៣ ពិន្ទុភាគរយ នៃ ផសស ក្នុងមួយឆ្នាំ នៅក្នុងយុទ្ធសាស្ត្រកៀរគរចំណូលឆ្នាំ ២០១៩-២០២៣។

៣-លទ្ធផលនៃការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២២ នៅក្នុងឆមាសទី ១ និង ការវាយតម្លៃការអនុវត្តសម្រាប់ឆ្នាំ ២០២២

៣.១-ស្ថានភាពម៉ាក្រូសេដ្ឋកិច្ចនៅក្នុងឆមាសទី ១ និងការវាយតម្លៃសម្រាប់ឆ្នាំ ២០២២

ផ្អែកលើសូចនាករសេដ្ឋកិច្ចសំខាន់ៗ ដែលសម្រេចបានក្នុង ឆមាសទី ១ គួបផ្សំនឹងការពិគ្រោះយោបល់ជាមួយនឹងភាគីពាក់ព័ន្ធក្នុងវិស័យសាធារណៈ និងឯកជន, កំណើនសេដ្ឋកិច្ចកម្ពុជាត្រូវបានវាយតម្លៃថានឹងសម្រេចបាន ក្នុងអត្រា ៥,៤% ក្នុងឆ្នាំ ២០២២ ទាបជាងការវាយតម្លៃកាលពីដើមឆ្នាំ (ដែលបានព្យាករណ៍ក្នុងអត្រា ៥,៦%) ដោយសារផលប៉ះពាល់នៃសង្គ្រាមរវាងរុស្ស៊ី និងអ៊ុយក្រែន តាមរយៈការកើនឡើងថ្លៃទំនិញគ្រប់ប្រភេទ ជាពិសេស ប្រេងឥន្ធនៈ និងវត្ថុធាតុដើមកសិកម្ម រួមមាន ដី និងថ្នាំសម្លាប់សត្វល្អិត។ ការកើនឡើងថ្លៃជារួម បានបង្កផលប៉ះពាល់ដល់សកម្មភាពចាយវាយ និងប្រើប្រាស់ក្នុងស្រុក ក៏ដូចជាជីវភាពរស់នៅរបស់ប្រជាជន។ ជាការឆ្លើយតប រាជរដ្ឋាភិបាលបានគិតគូរ និងបន្តអនុវត្តវិធានការអន្តរាគមន៍ រួមមាន ការឧបត្ថម្ភសាច់ប្រាក់ដល់ប្រជាជនក្រីក្រ និងជនងាយរងគ្រោះ, កម្មវិធីសាច់ប្រាក់ពលកម្ម និងការផ្តល់ប្រាក់ឧបត្ថម្ភដល់កម្មករ-និយោជិតក្នុងអំឡុងពេលព្យួរការងារជាដើម ដែលបានចូលរួមចំណែកទ្រទ្រង់ជីវភាពប្រជាជន និងសកម្មភាពអាជីវកម្ម និងចូលរួមចំណែកទ្រទ្រង់កំណើនសេដ្ឋកិច្ចជារួម។ ទន្ទឹមនេះ កំណើនសេដ្ឋកិច្ចសម្រាប់ឆ្នាំ ២០២២ ជារួម នឹងគាំទ្រដោយការបន្តនិន្នាការល្អប្រសើរនៃតម្រូវការខាងក្រៅ និងការសម្រេចបាននូវអត្រាខ្ពស់នៃការចាក់វ៉ាក់សាំង ដែលអនុញ្ញាតឱ្យមានការបើកប្រទេសឡើងវិញ ដែលបានធ្វើឱ្យសកម្មភាពសេដ្ឋកិច្ចក្នុងស្រុកចាប់ផ្តើមវិលត្រឡប់ទៅកម្រិតធម្មតាវិញ។

(ក)- **វិស័យឧស្សាហកម្មត្រូវបានប៉ាន់ស្មាននឹងមានកំណើន ៩,០% ខ្ពស់ជាងការរំពឹងទុក ដោយសារកំណើនល្អប្រសើរនៃអនុវិស័យកាត់ដេរ និងការបន្តកំណើនរឹងមាំនៃអនុវិស័យកម្មន្តសាលមិនមែនកាត់ដេរ ខណៈដែលអនុវិស័យសំណង់រំពឹងថានឹងបន្តនិន្នាការកើនឡើង ប៉ុន្តែក្នុងអត្រាកំណើនទាប។** ***អនុវិស័យកាត់ដេរ*** ត្រូវបានប៉ាន់ស្មានថានឹងសម្រេចបានកំណើន ក្នុងអត្រា ១០,៨% ដែលត្រូវបានឆ្លុះបញ្ចាំងដោយការបន្តនិន្នាការល្អប្រសើរនៃតម្រូវការខាងក្រៅ។ ការនាំចេញផលិតផលកាត់ដេរបានកើនឡើងគួរឱ្យកត់សម្គាល់ក្នុងអត្រា ៤០,៧% ក្នុងរយៈពេល ៥ ខែដំបូង នៃឆ្នាំ ២០២២ ធៀបនឹង -០,៦% ក្នុងរយៈពេលដូចគ្នា នៃឆ្នាំ ២០២១។ ទន្ទឹមនេះ ក្នុងរយៈពេលដូចគ្នា ការនាំចូលវត្ថុធាតុដើមកាត់ដេរ ក៏បានកើនឡើង ក្នុងរង្វង់ ២០,៣% ធៀបនឹង ២៣,៩% ដែលឆ្លុះបញ្ចាំងពីការបន្តនិន្នាការល្អប្រសើរនៃការនាំចេញផលិតផលកាត់ដេរនាពេលខាងមុខ។ ***អនុវិស័យកម្មន្តសាលមិនមែនកាត់ដេរ*** ត្រូវបានប៉ាន់ស្មានថានឹងរក្សាបានកំណើនរឹងមាំ ក្នុងអត្រា ១២,២% ដែលគាំទ្រដោយភាពរឹងមាំនៃតម្រូវការខាងក្រៅ, ការអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី និងការងើបឡើងវិញនៃតម្រូវការក្នុងស្រុក។ ជាក់ស្តែង ការនាំចេញផលិតផលកម្មន្តសាលមិនមែនកាត់ដេរ រួមមាន៖ កង់, គ្រឿងបង្ហុំអេឡិចត្រូនិក, គ្រឿងសង្ហារិម និងបន្ទះសូឡា ជាដើម (មិនរាប់បញ្ចូលមាស) ក្នុងរយៈពេល ៥ ខែដើមឆ្នាំ ២០២២ មានកំណើន ៣២,៥% ធៀបនឹង ៥២,០% ក្នុងរយៈពេលដូចគ្នានៃឆ្នាំ ២០២១។ ***អនុវិស័យសំណង់***

ត្រូវបានប៉ាន់ស្មានថានឹងបន្តងើបឡើងវិញក្នុងល្បឿនយឺត ពោលក្នុងអត្រា ៣,០% ដោយសារការបន្តថយថយសកម្មភាព សំណង់បម្រើឱ្យវិស័យទេសចរណ៍ និងពាណិជ្ជកម្ម ខណៈដែលសកម្មភាពសំណង់លំនៅឋានថ្លៃទាប និងមធ្យមនៅបន្តអត្រាកំណើនទាប។ ជាក់ស្តែង ផ្អែកលើទិន្នន័យ ៥ ខែដើមឆ្នាំ ចំនួនគម្រោងសំណង់ដែលបានអនុម័តបម្រើឱ្យវិស័យពាណិជ្ជកម្ម និងទេសចរណ៍បានធ្លាក់ចុះ ក្នុងអត្រា -៣៦,១% និង -២០,០% រៀងគ្នា។ យ៉ាងណាមិញ, ចំនួនសកម្មភាពសំណង់លំនៅឋាន ជាពិសេសសំណង់ល្វែង និងវីឡា បានកើនឡើងប្រមាណ ១៨៣,២% និង ៦០,៤% រៀងគ្នាក្នុងឆ្នាំ ២០២២ គិតត្រឹម ៥ ខែដើមឆ្នាំ។

(ខ)-**វិស័យសេវាកម្ម ត្រូវបានប៉ាន់ស្មានថានឹងសម្រេចបានកំណើន ក្នុងអត្រា ៤,៣% ដោយសារការងើបឡើងវិញនៃអនុវិស័យសណ្ឋាគារ និងភោជនីយដ្ឋាន និងការបន្តនិន្នាការកើនឡើងនៃអនុវិស័យគាំទ្ររួមមាន អនុវិស័យលក់ដុំ-រាយ, និងដឹកជញ្ជូន និងគមនាគមន៍ ស្របពេលដែលអនុវិស័យអចលនទ្រព្យក៏រំពឹងថានឹងបន្តងើបឡើង ប៉ុន្តែក្នុងអត្រាកំណើនទាប។** ***អនុវិស័យសណ្ឋាគារ និងភោជនីយដ្ឋាន*** ត្រូវបានប៉ាន់ស្មានថានឹងងើបឡើងវិញក្នុងអត្រា ១៦,៥% ដោយសារការរំពឹងទុកនៃការកើនឡើងចំនួនភ្ញៀវទេសចរជាតិ និងអន្តរជាតិ ដែលមួយផ្នែកបណ្តាលមកពីភាពស្រាកស្រាន្តនៃការរីករាលដាលនៃជំងឺកូវីដ-១៩ ដែលអនុញ្ញាតឱ្យរាជរដ្ឋាភិបាលបើកប្រទេសឡើងវិញជាផ្លូវការ និងមួយផ្នែកទៀតដោយសារការងើបឡើងវិញនៃទំនុកចិត្តនៃការធ្វើដំណើរ។ ជាក់ស្តែង គិតត្រឹម ៥ ខែដើមឆ្នាំ ២០២២, ភ្ញៀវទេសចរអន្តរជាតិបានកើនឡើងគួរឱ្យកត់សម្គាល់ក្នុងអត្រា ២៦៤,៨% ធៀបនឹង -៩២,២% ក្នុងរយៈពេលដូចគ្នានៃឆ្នាំ ២០២១។ ទន្ទឹមនេះ ក្នុងរយៈពេល ៥ ខែដើមឆ្នាំ, ភ្ញៀវទេសចរជាតិក៏មានសម្នុះកើនឡើងផងដែរ ក្នុងអត្រា ២០៨,៧% ធៀបនឹង -៣២,៩% ក្នុងឆ្នាំ ២០២១។ ***អនុវិស័យអចលនទ្រព្យ*** ត្រូវបានប៉ាន់ស្មានថានឹងបន្តនិន្នាការកើនឡើង ប៉ុន្តែក្នុងល្បឿនយឺត ក្នុងអត្រា ២,៥% ដោយសារការបន្តថយថយសកម្មភាពទិញ-លក់អចលនទ្រព្យថ្លៃខ្ពស់ ពិសេសខុនដូ និងអាផាតមិន ខណៈដែលសកម្មភាពទិញ-លក់/ជួលអចលនទ្រព្យថ្លៃទាប និងមធ្យម ជាពិសេសលំនៅឋាន រំពឹងថានៅបន្តសកម្មភាព។ ជាក់ស្តែង គិតត្រឹម ៤ ខែដើមឆ្នាំ ចំនួនលក់លំនៅឋាន (ល្វែង និងវីឡា) បានកើនឡើងក្នុងអត្រា ៦,៧% ក្នុងឆ្នាំ ២០២២។ ***អនុវិស័យលក់ដុំ-រាយ*** ត្រូវបានវាយតម្លៃថានឹងបន្តងើបឡើងវិញ ក្នុងរង្វង់ ៤,៣% ដោយសារការងើបឡើងវិញនៃសកម្មភាពចាយវាយ និងប្រើប្រាស់ក្នុងស្រុក។ ជាក់ស្តែង បន្ទាប់ពីការបើកប្រទេសឡើងវិញនៅត្រីមាសទី ៤ ឆ្នាំ ២០២១ និងការបន្ធូរបន្ថយរបាំងធ្វើដំណើរកាលពីត្រីមាសទី ១ ឆ្នាំ ២០២២ កន្លងទៅ សកម្មភាពប្រើប្រាស់ក្នុងស្រុកបានងើបឡើងវិញគួរឱ្យកត់សម្គាល់ ដោយផ្អែកលើសន្ទស្សន៍ Google Mobility ដែលឆ្លុះបញ្ចាំងតាមរយៈការកើនឡើងក្នុងរង្វង់ ១០%។ ***អនុវិស័យដឹកជញ្ជូន និងគមនាគមន៍*** ត្រូវបានប៉ាន់ស្មានថានឹងមានកំណើន ក្នុងអត្រា ៦,១% ដោយសារកំណើនរឹងមាំនៃសកម្មភាពគមនាគមន៍ និងការងើបឡើងនៃសកម្មភាពដឹកជញ្ជូន ឆ្លុះបញ្ចាំងតាមរយៈការងើបឡើងនៃវិស័យគាំទ្រសំខាន់ៗ រួមមាន៖ វិស័យ ទេសចរណ៍ និងវិស័យកាត់ដេរ។ ជាក់ស្តែង ការនាំចូលរថយន្ត (បរិមាណ) បានកើនឡើង ១៣,៥% ក្នុងរយៈពេល ៤ ខែដើមឆ្នាំ ធៀបនឹង -២២,៩% រយៈពេលដូចគ្នាក្នុងឆ្នាំ ២០២១ ដែលឆ្លុះបញ្ចាំងពីការកើនឡើងនៃសកម្មភាពដឹកជញ្ជូនក្នុងស្រុក។ ទន្ទឹមនេះ សកម្មភាពដឹកជញ្ជូនតាមកំពង់ផែក៏មានភាពមមាញឹកក្នុងត្រីមាសទី ១ ឆ្នាំ ២០២២។ ជាក់ស្តែង ទំនិញឆ្លងកាត់ (cargo volume) ឆ្លងកាត់កំពង់ផែស្វយ័តភ្នំពេញ និងកំពង់ផែស្វយ័តក្រុងព្រះសីហនុ បានកើនឡើងគួរឱ្យកត់សម្គាល់ ក្នុងអត្រា ៣១,៥% និង ១២,១% រៀងគ្នា។

(គ)-**វិស័យកសិកម្ម ត្រូវបានប៉ាន់ស្មានថានឹងសម្រេចបានកំណើនទាប ក្នុងអត្រា ០,៧% ដោយសារភាពអាក់អូលនៃខ្សែច្រវាក់ផ្គត់ផ្គង់ និងការកើនឡើងថ្លៃដើមផលិត បន្ទាប់ពីមានការតឹងតន្តឹងច្រកព្រំដែនរបស់ប្រទេសចិន និងការផ្ទុះឡើងនៃសង្គ្រាមរវាងរុស្សី និងអ៊ុយក្រែន។** ***អនុវិស័យដំណាំ*** ត្រូវបានប៉ាន់ស្មានថា

នឹងសម្រេចបានកំណើន ១,៤% ទាបជាងការរំពឹងទុក ដោយសារកាតព្វកិច្ចក្នុងការនាំចេញផលិតផលកសិកម្មទៅកាន់ប្រទេសចិន ជាពិសេសផលិតផលកសិកម្មស្រស់ បន្ទាប់ពីមានការតឹងតែងនូវច្រកព្រំដែនរបស់ប្រទេសចិន តាមរយៈការអនុវត្តគោលនយោបាយគ្មានកូវីដ-១៩។ បន្ថែមពីនេះ ការផ្ទុះឡើងនៃសង្គ្រាមរវាងរុស្សីនិងអ៊ុយក្រែន បានដាក់សម្ពាធបន្ថែមមកលើខ្សែច្រវាក់ផ្គត់ផ្គង់ និងជំរុញឱ្យមានការកើនឡើងថ្លៃដើមផលិតមកលើការដឹកជញ្ជូន, ជីកសិកម្ម និងថ្នាំសម្លាប់សត្វល្អិតជាដើម។ ជាក់ស្តែង គិតត្រឹមរយៈពេល ៥ ខែដើមឆ្នាំ ទិន្នន័យនាំចេញជាបរិមាណ បានធ្លាក់ចុះគួរឱ្យកត់សម្គាល់ ដូចជា ស្វាយ -១០០,០% ខណៈដំណាំមួយចំនួនទៀតមានកំណើនថមថយ រួមមាន ដំឡូងមី ១៤,៦% កៅស៊ូ ៥,៣% និងចេក ៤,២%។ ***អនុវិស័យនេសាទ*** ត្រូវបានប៉ាន់ស្មានថានៅបន្តកំណើនអវិជ្ជមាន ក្នុងអត្រា -០,៥% ដោយសារបញ្ហាប្រឈមជាច្រើនសម្ព័ន្ធក្នុងទីផ្សារផ្គត់ផ្គង់ត្រីនៅមិនទាន់បានដោះស្រាយ ដែលបានធ្វើឱ្យកសិដ្ឋានចិញ្ចឹមត្រីកាត់បន្ថយផលិតកម្ម និងខ្លះទៀតសម្រេចចិត្តបោះបង់ចោលការចិញ្ចឹមទាំងស្រុង។ ជាក់ស្តែង គិតត្រឹមរយៈពេល ៥ ខែ ដើមឆ្នាំ ផលិតកម្មជារួមមានការធ្លាក់ចុះខ្លាំង ក្នុងអត្រា ៤៥% ក្នុងនោះ ផលចាប់ទឹកសាបធ្លាក់ចុះ -២៩,៩% និង ផលិតកម្មវារីវប្បកម្មធ្លាក់ចុះ -៨១,៧%។ ***អនុវិស័យចិញ្ចឹមសត្ត*** ត្រូវបានប៉ាន់ស្មានថានឹងបន្តសម្រេចបានកំណើនល្អប្រសើរ ក្នុងអត្រា ១,០% បន្តជំរុញដោយការពង្រីកផលិតកម្ម ជាពិសេសជ្រូក ស្របពេលដែលសកម្មភាពសេដ្ឋកិច្ចបន្តងើបឡើងវិញ។ ការបន្តកាត់បន្ថយការនាំចូលជ្រូកពីបរទេស ក្នុងទិសដៅទប់ស្កាត់ការរីករាលដាលនៃជំងឺប៉េស្តជ្រូកអាហ្វ្រិក គួបផ្សំនឹងតម្រូវការនិងថ្លៃខ្ពស់ ក៏ជាកត្តាជំរុញ ឱ្យផលិតករមានទឹកចិត្តក្នុងការបង្កើនផលិតកម្ម។

តារាងទី ២ៈ កំណើនសេដ្ឋកិច្ចតាមវិស័យ ២០១៩-២០២២

កំណើនពិត	២០១៩	២០២០	២០២១	២០២២ ប៉ាន់
វិស័យកសិកម្ម	**-០,៥%**	**០,៦%**	**១,១%**	**០,៧%**
ដំណាំ	០,៦%	០,៦%	២,៦%	១,៤%
ការចិញ្ចឹមសត្ត	-២,៦%	១,២%	២,២%	១,០%
នេសាទ	-១,៦%	-០,៥%	-២,៤%	-០,៥%
ព្រៃឈើ	-១,៨%	-១,២%	-១,៤%	-១%
វិស័យឧស្សាហកម្ម	**១១,៣%**	**-១,៤%**	**៨,៦%**	**៩,០%**
កាត់ដេរ	៦,៦%	-៦,១%	១០,៨%	១០,៨%
សំណង់	២០,៨%	-១,៨%	១,១%	៣,០%
កម្មន្តសាលមិនមែនកាត់ដេរ	១០,៣%	១០,៤%	១៣,៩%	១២,២%
វិស័យសេវាកម្ម	**៦,២%**	**-៦,៣%**	**-១,៩%**	**៤,៣%**
សណ្ឋាគារ និងភោជនីយដ្ឋាន	៣,១%	-៣២,២%	-៣៩,៥%	១៦,៥%
លក់ដុំ-រាយ	៦,៥%	-៥,៤%	១,៦%	៤,៣%
ដឹកជញ្ជូន និងគមនាគមន៍	៨,៤%	-២,៧%	២,៨%	៦,១%
អចលនទ្រព្យ	៧,០%	-៥,០%	០,៥%	២,៥%
អនុវិស័យសេវាកម្មផ្សេងទៀត	៥,៥%	០,១%	១,៥%	២,៥%
កំណើន ផសស ពិត	**៧,១%**	**-៣,១%**	**៣,០%**	**៥,៤%**

ប្រភព÷ ក្រសួងជាក់ស្តែងវិទ្យាស្ថានជាតិស្ថិតិ (២០១៩-២០២១) និងការប៉ាន់ស្មានសម្រាប់ឆ្នាំ ២០២២ ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (ខែ ឧសភា ឆ្នាំ ២០២២)

ទោះជាយ៉ាងនេះក្តី, កម្ពុជាកំពុងតែទទួលរងការគំរាមកំហែងថ្មីមួយទៀត ដែលអាចក្លាយជាវិបត្តិ, កើតចេញពីស្ថានភាពមិនអំណោយផលនៃសេដ្ឋកិច្ចពិភពលោក ដោយសារការថមថយកំណើនសកល និងជាពិសេស ការកើនឡើងខ្ពស់នូវអត្រាអតិផរណាជាងការរំពឹងទុក។ គួរកត់សម្គាល់ផងដែរថា អតិផរណាបានចាប់ផ្តើមកើនឡើង តាំងពីមុនពេលមានវិបត្តិនៃជំងឺកូវីដ-១៩ មកម្ល៉ះ ហើយបន្តកើនឡើងខ្លាំងថែមទៀត ក្នុងពេលនៃវិបត្តិជំងឺកូវីដ-១៩ ដោយសារប្រទេសធំៗ បានបង្កើនចំណាយសាច់ប្រាក់យ៉ាងច្រើនសន្ធឹកសន្ធាប់, ក៏ដូចជាការអនុវត្តវិធានការរូបិយវត្ថុផ្សេងទៀត ដើម្បីដោះស្រាយបញ្ហាសង្គម-សេដ្ឋកិច្ចរបស់ខ្លួន ដើម្បីជួយដល់អ្នកអត់ការងារធ្វើ, ក្រុមជនដែលទទួលរងផលប៉ះពាល់ដោយសារការបិទខ្ទប់ និងក្រុមហ៊ុនដែលរងផលប៉ះពាល់។ល។ បន្ថែមពីនេះ ការអូសបន្លាយនៃសង្គ្រាមរវាងរុស្ស៊ី និងអ៊ុយក្រែន ក៏បានដាក់សម្ពាធបន្ថែមនិងបង្កើនល្បឿនហាក់ឡើងនៃអតិផរណា តាមរយៈការឡើងថ្លៃប្រេង និងថ្លៃម្ហូបអាហារ ដែលជាហេតុធ្វើឱ្យទំនិញគ្រប់មុខឡើងថ្លៃ។ ក្រៅពីសង្គ្រាមនៅអ៊ុយក្រែន, បញ្ហាទំនាស់ភូមិសាស្ត្រនយោបាយតំបន់ ក៏កាន់តែតឹងតែង ដែលធ្វើឱ្យប៉ះពាល់ដល់ការធ្វើពាណិជ្ជកម្មអន្តរជាតិ និងអាចបង្ក ឱ្យមានការរាំងស្ទះដល់ខ្សែច្រវាក់ផ្គត់ផ្គង់ពិភពលោក។ ជារួមការកើនឡើងនូវអតិផរណានាពេលនេះ បណ្តាលមកពីទាំងផ្នែកផ្គត់ផ្គង់ (Supply Side) និង ទាំងផ្នែកតម្រូវការ (Demand Side)។ ប្រការនេះបាន និងកំពុងធ្វើឱ្យកំណើនសេដ្ឋកិច្ចពិភពលោកប្រឈមនឹងការថមថយជាងការរំពឹងទុក ហើយអាចនាំទៅដល់វិបត្តិនៃការធ្លាក់ចុះសេដ្ឋកិច្ចសកល (Recession) និងជាលទ្ធផលអាចនឹងធ្វើឱ្យការងើបឡើងវិញនៃសេដ្ឋកិច្ចកម្ពុជាមានកម្រិតទាបជាងការរំពឹងទុកផងដែរ។

ជាមួយគ្នានេះ សេដ្ឋកិច្ចកម្ពុជាកំពុងប្រឈមនឹងហានិភ័យទាំងក្នុង និងក្រៅប្រទេសមួយចំនួន ដូចខាងក្រោម៖

ទី១-ផ្នែកក្រៅប្រទេស៖ សេដ្ឋកិច្ចកម្ពុជាអាចប្រឈមនឹងហានិភ័យមួយចំនួន រួមមាន៖ ការបន្តអូសបន្លាយនិងកាពតានតឹងនៃសង្គ្រាមរវាងរុស្ស៊ី និងអ៊ុយក្រែន, ការតឹងតប្ដឹងគោលនយោបាយរូបិយវត្ថុ ជាពិសេសសហរដ្ឋអាមេរិក, ការថមថយសេដ្ឋកិច្ចចិន, ភាពអាក់អួលនៃច្រវាក់ផលិតកម្មសកល និងការកើនឡើងសម្ពាធអតិផរណា, ភាពមិនប្រាកដប្រជានៃប្រព័ន្ធអនុគ្រោះពន្ធ, និងការប្រែប្រួលអាកាសធាតុ និងគ្រោះធម្មជាតិ។

ទី២-ផ្នែកក្នុងស្រុក៖ ទន្ទឹមនឹងការកើនឡើងនៃហានិភ័យខាងក្រៅ, កម្ពុជានៅតែបន្តប្រឈមនឹងបញ្ហាក្នុងស្រុកមួយចំនួន ដែលមានចរិតជារចនាសម្ព័ន្ធ។ បញ្ហាប្រឈមទាំងនោះ រួមមាន៖ មូលដ្ឋានសេដ្ឋកិច្ចតូចចង្អៀត និងល្បឿននៃការធ្វើពិពិធកម្មមានភាពយឺតយ៉ាវ, ថ្លៃដើមធុរកិច្ចនៅមានកម្រិតខ្ពស់, បរិមាណ និងគុណភាពនៃកម្លាំងពលកម្មជំនាញ មិនទាន់ឆ្លើយតបទៅនឹងតម្រូវការទីផ្សារ, ភាពមានកម្រិតនៃប្រព័ន្ធសុខាភិបាល និងប្រព័ន្ធគាំពារសង្គម, និងភាពមានកម្រិតនៃចំណេះដឹង និងជំនាញក្នុងការចាប់យកបច្ចេកវិទ្យាឌីជីថល។

៣.២-លទ្ធផលនៃការអនុវត្តថវិកាឆមាសទី ១ និងការវាយតម្លៃការអនុវត្តសម្រាប់ឆ្នាំ ២០២២

៣.២.១-ការអនុវត្តចំណូលឆមាសទី ១ ឆ្នាំ ២០២២

ក-ចំណូលថ្នាក់ជាតិ

ចំណូលសរុបប្រចាំឆមាសទី ១ អនុវត្តបានចំនួន ១៤ ១០១ ៨៥០ លានរៀល ស្មើនឹង ៥៧,0% នៃច្បាប់ហិរញ្ញវត្ថុ គឺខ្ពស់ជាង ១,២ ពិន្ទុភាគរយ ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២១ ដែលអនុវត្តបាន ៥៥,៨% នៃច្បាប់ហិរញ្ញវត្ថុ, បើគិតចំណូលជាសាច់ប្រាក់ គឺកើនឡើង ២១,៥% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២១ ក្នុងនោះ៖

-ចំណូលចរន្ត អនុវត្តបានចំនួន ១២ ៦៩៣ ៥៨៥ លានរៀល ស្មើនឹង ៥៧,៣% នៃច្បាប់ហិរញ្ញវត្ថុ គឺខ្ពស់ជាង ៣,៨ ពិន្ទុភាគរយ ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២១ ដែលអនុវត្តបាន ៥៣,៥% នៃច្បាប

ហិរញ្ញវត្ថុ, បើគិតជាសាច់ប្រាក់គឺកើនឡើង ២០,៤% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២១ ដោយសារការ-កំណត់ចំណូលសម្រាប់ឆ្នាំ ២០២២ គឺទាបជាងចំណូលសម្រាប់ឆ្នាំ ២០២១ ដែលក្នុងនោះ **ចំណូលសារពើពន្ធ** អនុវត្តបានចំនួន ១២ ០១៧ ៥១២ លានរៀល ស្មើនឹង ៥៩,៤% នៃច្បាប់ហិរញ្ញវត្ថុ គឺខ្ពស់ជាង ៤,១% ពិន្ទុ-ភាគរយ ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២១ ដែលអនុវត្តបាន ៥៥,៣% នៃច្បាប់ហិរញ្ញវត្ថុ, បើគិតចំណូលជាសាច់ប្រាក់គឺកើនឡើង ២៤,០% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២១ និង **ចំណូលមិនមែនសារពើពន្ធ** អនុវត្តបានចំនួន ៦៧៦ ០៧៣ លានរៀល ស្មើនឹង ៣៥,០% នៃច្បាប់ហិរញ្ញវត្ថុ គឺទាបជាង ៣,៩ ពិន្ទុភាគរយ ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២១ ដែលអនុវត្តបាន ៣៨,៩% នៃច្បាប់ហិរញ្ញវត្ថុ, បើគិតចំណូលជាសាច់ប្រាក់គឺថយចុះ ២០,៥% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២១ ។

ជារួម ចំណូលសារពើពន្ធនៅអនុវត្តបានល្អប្រសើរ ពោលគឺខ្ពស់ជាងឆ្នាំ ២០២១ ធៀបនឹងរយៈពេល ៦ ខែដើមឆ្នាំដូចគ្នា ប៉ុន្តែ ចំណូលមិនមែនសារពើពន្ធអនុវត្តបានទាប ដោយសារប្រភពចំណូលសារពើពន្ធសំខាន់ៗ នៅទទួលរងនូវផលប៉ះពាល់ខ្លាំងពីជំងឺកូវីដ-១៩។ ទោះជាយ៉ាងនេះក្តី, តាមការប៉ាន់ប្រមាណរហូតដល់ដំណាច់ឆ្នាំ ២០២២, *ចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធអាចនឹងសម្រេចបាន ១០៣,៥% នៃច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០២២ គឺខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុចំនួន ៣,៥%* ។ តាមការវាយតម្លៃនេះ **ចំណូលចរន្ត នឹងសម្រេចបានខ្ពស់ជាងផែនការ ១៩០ លានដុល្លារអាម៉េរិក ដោយសារចំណូលមិនមែនសារពើពន្ធនឹងសម្រេចខ្ពស់ជាងផែនការប្រមាណ ៥ លានដុល្លារអាម៉េរិក, ចំណូលពន្ធដារអាចសម្រេចបានខ្ពស់ជាងផែនការ ២២៩ លានដុល្លារអាម៉េរិក តែចំណូលគយអាចទាបជាងផែនការ ៤៤ លានដុល្លារអាម៉េរិក។**

ឯកតា៖ លានរៀល

តារាងទី ៣៖ តារាងចំណូលថវិការដ្ឋ (ថ្នាក់ជាតិ)					
ប្រតិបត្តិការ	ឆ្នាំ ២០២២				
	ច្បាប់	អនុវត្តឆមាសទី ១		ប៉ាន់ស្មានប្រចាំឆ្នាំ	
	ហិរញ្ញវត្ថុ	ទឹកប្រាក់	%ច្ប.	ទឹកប្រាក់	%ច្ប.
I. ចំណូលឆ្លងកាត់អង្គនាយកដ្ឋានរតនាគារជាតិ	២៤ ៧៣០ ៨៨២	១៤ ១០១ ៨៥០	៥៧,០%	២៦ ១៤៥ ០២២	១០៥,៧%
១. ចំណូលចរន្ត	២២ ១៥៧ ៣៤៣	១២ ៦៩៣ ៥៨៥	៥៧,៣%	២២ ៩៣១ ៣១៥	១០៣,៥%
ក. ចំណូលសារពើពន្ធ	២០ ២២៧ ០០៥	១២ ០១៧ ៥១២	៥៩,៤%	២០ ៩៧៩ ៩០៤	១០៣,៧%
- ចំណូលគយ និងរដ្ឋាករ	១០ ៤០០ ០០៥	៥ ១៧៨ ៦៤៩	៤៩,៨%	១០ ២២១ ៨៤០	៩៨,៣%
- ចំណូលពន្ធដារ	៩ ៨២៧ ០០០	៦ ៨៣៨ ៨៦៣	៦៩,៦%	១០ ៧៥៨ ០៦៣	១០៩,៥%
ខ. ចំណូលមិនមែនសារពើពន្ធ	១ ៩៣០ ៣៣៨	៦៧៦ ០៧៣	៣៥,០%	១ ៩៥១ ៤១២	១០១,១%
- ចំណូលពីទ្រព្យសម្បត្តិរដ្ឋ (អគ្គ.ទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ)	២១៩ ៦០៧	៣៥៧ ១២៣	១៦២,៦%	២២១ ៣៩៩	១០០,៨%
- ចំណូលមិនមែនសារពើពន្ធ (អគ្គ.ទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ)	១ ៥៥៩ ៨១១	៣០៧ ៥៨៥	១៩,៧%	១ ៥៧៩ ០៩៣	១០១,២%
- ចំណូលមិនមែនសារពើពន្ធផ្សេងៗ (ចំណូលកាតព្វកិច្ចកាស៊ីណូ និងឆ្នោត)	១៥០ ៩២០	១១ ៣៦៥	៧,៥%	១៥០ ៩២០	១០០,០%
២. ចំណូលមូលធន	២ ៥៧៣ ៥៣៩	១ ៤០៨ ២៦៥	៥៤,៧%	៣ ២១៣ ៧០៦	១២៤,៩%
-មូលធនក្នុងប្រទេស	១ ៣០៥ ២៥៩	១៨ ៨៩៦	១,៤%	១ ២៨១ ០០២	៩៨,១%
-មូលនិធិទ្រទ្រង់ថវិកា	១ ២៦៨ ២៨០	១ ៣៨៩ ៣៦៩	១០៩,៥%	១ ៩៣២ ៧០៤	១៥២,៤%

-**ចំណូលមូលធនថវិការដ្ឋ** អនុវត្តបានចំនួន ១ ៤០៨ ២៦៥ លានរៀល គឺស្មើនឹង ៥៤,៧% នៃច្បាប់ហិរញ្ញវត្ថុ។ ក្នុងនោះ **ចំណូលមូលធនក្នុងប្រទេស** អនុវត្តបានចំនួន ១៨ ៨៩៦ លានរៀល ស្មើនឹង ១,៤% នៃច្បាប់ហិរញ្ញវត្ថុ គឺទាបជាង ១២,០ ពិន្ទុភាគរយ ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២១ ដែលអនុវត្តបាន ១៣,៤% នៃច្បាប់ហិរញ្ញវត្ថុ។ ចំពោះ**ចំណូលមូលនិធិទ្រទ្រង់ថវិកា** អនុវត្តបានចំនួន ១ ៣៨៩ ៣៦៩ លានរៀល ស្មើនឹង ១០៩,៥% នៃច្បាប់ហិរញ្ញវត្ថុ។

ក.១-**ចំណូលសារពើពន្ធ** សរុបសម្រាប់ឆមាសទី ១ ឆ្នាំ ២០២២ អនុវត្តបាន ៥៩,៤% នៃច្បាប់ហិរញ្ញវត្ថុ ដែលក្នុងនោះ៖

• **ចំណូលគយនិងរដ្ឋាករ** អនុវត្តបានចំនួន ៥ ១៧៨ ៦៤៩ លានរៀល **ស្មើនឹង ៤៩,៨% នៃច្បាប់ហិរញ្ញវត្ថុ** គឺខ្ពស់ជាង ៣,៥ ពិន្ទុភាគរយ ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២១ ដែលអនុវត្តបាន ៤៦,៣% នៃច្បាប់ហិរញ្ញវត្ថុ, បើគិតជាសាច់ប្រាក់ ចំណូលគយនិងរដ្ឋាករកើនឡើង ១៧,៨% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២១។ ក្នុងនោះ ចំណូលបានមកពីយុទ្ធនាការប្រមូលពន្ធនិងអាករលើយានយន្តមានស្រាប់ក្នុងប្រទេសមានចំនួន ១៣៤ ២៩៧ លានរៀល ត្រូវជា ២,៦% នៃចំណូលប្រមូលដោយគយនិងរដ្ឋាករក្នុងឆមាសទី ១ ឆ្នាំ ២០២២ ដែលយុទ្ធនាការនេះបានបិទបញ្ចប់នៅដំណាច់ខែ មិថុនា ឆ្នាំ ២០២២។ គួរកត់សម្គាល់ផងដែរថា ចំណូលគយនិងរដ្ឋាករតាមបណ្តាខែក្នុងឆមាសទី ១ ឆ្នាំ ២០២២ មាននិន្នាការងើបឡើងវិញបណ្តើរៗ បន្ទាប់ពីរាជរដ្ឋាភិបាលបានបើកប្រទេសឡើងវិញ។ ប៉ុន្តែ ទន្ទឹមគ្នានេះ ចំណូលបាត់បង់ដោយសារការអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីក្នុងក្របខ័ណ្ឌអាស៊ាន និងរវាងអាស៊ានជាមួយដៃគូអាស៊ានផ្សេងទៀតសរុប ក្នុងឆមាសទី ១ ឆ្នាំ ២០២២ មានរហូតដល់ប្រមាណ ៧៣៨ ៥៧៦ លានរៀល និងពន្ធអាករជាបន្ទុករបស់រដ្ឋមានរហូតដល់ប្រមាណ ៧ ៤០៧ ៤១០ លានរៀល។

បើពិនិត្យលើរចនាសម្ព័ន្ធពន្ធអាករគយដែលត្រូវបានកត់ត្រាដោយអគ្គនាយកដ្ឋានរតនាគារជាតិ នោះឃើញថា (១)-ពន្ធលើការនាំចូលអនុវត្តបាន ៥០,១% នៃច្បាប់ហិរញ្ញវត្ថុ ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២១ គឺកើនឡើង ៦,០ ពិន្ទុភាគរយ, (២)-អាករលើការនាំចេញអនុវត្តបាន ៦០,៦% នៃច្បាប់ហិរញ្ញវត្ថុ ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២១ គឺថយចុះ ១១០,៣ ពិន្ទុភាគរយ ដោយសារការនាំចេញទំនិញផ្សេងៗមានដំណើរការល្អប្រសើរឡើងវិញ (៣)-អាករពិសេសលើការនាំចូលអនុវត្តបាន ៤៩,៤% នៃច្បាប់ហិរញ្ញវត្ថុ ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២១ គឺកើនឡើង ២,៤ ពិន្ទុភាគរយ និង (៤)-អាករលើតម្លៃបន្ថែមលើការនាំចូលអនុវត្តបាន ៤៩,៧% នៃច្បាប់ហិរញ្ញវត្ថុ ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២១ គឺកើនឡើង ៣,៣ ពិន្ទុភាគរយ។

ទន្ទឹមនេះ បើពិនិត្យលើប្រភពចំណូលសំខាន់ៗ នោះឃើញថា៖

- **ចំណូលពីមុខទំនិញចម្រុះ** ដែលគ្របដណ្តប់ប្រមាណ ២៨,១% នៃចំណូលសរុប បានកើនឡើង ១០,១% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២១។
- **ចំណូលពីមុខទំនិញយានយន្តនិងគ្រឿងចក្រ** ដែលគ្របដណ្តប់ប្រមាណ ៤៤,១% នៃចំណូលសរុប បានកើនឡើង ១៤,២% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២១ ។
- **ចំណូលពីមុខទំនិញផលិតផលតេលសិលា** ដែលគ្របដណ្តប់ប្រមាណ ២១,៦% នៃចំណូលសរុប បានកើនឡើង ១,៥% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២១។ បរិមាណ

នៃការនាំចូល ប្រេងសាំងកើនឡើង ១៩,៥% ប្រេងម៉ាស៊ូតថយចុះ ១៨,១% និងប្រេងយន្តហោះកើនឡើង ៥,៤%។

- **ចំណូលពីមុខទំនិញគ្រឿងសំណង់** ដែលគ្របដណ្តប់ប្រមាណ ៤,៦% នៃចំណូលសរុប បានកើនឡើង ៩,២% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២១។
- កម្រៃនិងចំណូលផ្សេងៗ ដែលគ្របដណ្តប់ប្រមាណ ១,៦% នៃចំណូលសរុប បានកើនឡើង ១១,៩% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២១។

ជារួម ការប្រមូលចំណូលគយនិងរដ្ឋាករ ក្នុងឆមាសទី ១ ឆ្នាំ ២០២២ មាននិន្នាការដើរបន្តិចម្តងៗ ក្រោយពីរដ្ឋាភិបាលបានបើកប្រទេសឡើងវិញ។ ដូចនេះ **តាមការប៉ាន់ស្មានរហូតដល់ដំណាច់ឆ្នាំ ចំណូលគយ និងរដ្ឋាករអាចនឹងសម្រេចបានប្រមាណ ៩៨,៣% នៃច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០២២**។

• **ចំណូលពន្ធដារ** (ថ្នាក់ជាតិ) អនុវត្តបានចំនួន ៦ ៨៣៨ ៨៦៣ លានរៀល **ស្មើនឹង ៦៩,៦% នៃច្បាប់ហិរញ្ញវត្ថុ**, គឺខ្ពស់ជាង ៣,៦ ពិន្ទុភាគរយ ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២១ ដែលអនុវត្តបាន ៦៦,០% នៃច្បាប់ហិរញ្ញវត្ថុ, បើគិតជាសាច់ប្រាក់ ចំណូលពន្ធដារកើនឡើង ២៩,២% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២១ គឺដោយសារ៖

- ពន្ធលើប្រាក់ចំណូលអនុវត្ត ៩០,៥% នៃច្បាប់ហិរញ្ញវត្ថុ, បើគិតចំណូលជាសាច់ប្រាក់កើន ២៩,៨% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២១,

- ពន្ធលើប្រាក់បៀវត្សអនុវត្តបាន ៦៥,៤% នៃច្បាប់ហិរញ្ញវត្ថុ, បើគិតជាចំណូលសាច់ប្រាក់កើន ២៦,៩% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២១,

- អាករលើតម្លៃបន្ថែម (របបផ្ទៃក្នុង) អនុវត្តបាន ៤៧,៥% នៃច្បាប់ហិរញ្ញវត្ថុ, បើគិតចំណូលជាសាច់ប្រាក់កើន ២៧,៧% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២១,

- អាករពិសេសលើទំនិញ និងសេវាក្នុងស្រុក អនុវត្តបាន ៥៤,០% នៃច្បាប់ហិរញ្ញវត្ថុ, បើគិតចំណូលជាសាច់ប្រាក់កើនឡើង ៣៦,១% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២១។

ជារួម ការប្រមូលចំណូលពន្ធដារ ឆមាសទី ១ ឆ្នាំ ២០២២ នៅតែបន្តសម្រេចបានលទ្ធផលល្អប្រសើរ ដែលឆ្លុះបញ្ចាំងឱ្យឃើញពីប្រសិទ្ធភាពនៃកិច្ចខិតខំប្រឹងប្រែង ក្នុងការអនុវត្តនូវផែនការយុទ្ធសាស្ត្រ និងផែនការប្រតិបត្តិរបស់អគ្គនាយកដ្ឋានពន្ធដារ ព្រមទាំងបានដាក់ចេញនូវគោលនយោបាយបន្ធូរបន្ថយពន្ធដើម្បីទ្រទ្រង់ដល់ដំណើរការអាជីវកម្មមួយចំនួនដែលរងនូវផលប៉ះពាល់ដោយសារការរីករាលដាលនៃជំងឺកូវីដ-១៩ និងការបើកប្រទេសឡើងវិញ។ *ដូចនេះ តាមការប៉ាន់ស្មានរហូតដល់ដំណាច់ឆ្នាំ ចំណូលពន្ធដារ(ថ្នាក់ជាតិ) អាចនឹងសម្រេចបានប្រមាណ ១០៩,៥% នៃច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០២២*។

ក.២-**ចំណូលមិនមែនសារពើពន្ធ** អនុវត្តបានចំនួន ៦៧៦ ០៧៣ លានរៀល **ស្មើនឹង ៣៥,០% នៃច្បាប់ហិរញ្ញវត្ថុ** គឺទាបជាង ៣,៩ ពិន្ទុភាគរយ ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២១ ដែលអនុវត្តបានចំនួន ៣៨,៩% នៃច្បាប់ហិរញ្ញវត្ថុ, បើគិតចំណូលជាសាច់មានការថយចុះ ២០,៥% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២១ ក្នុងនោះ៖

• **ចំណូលពីទ្រព្យសម្បត្តិរដ្ឋ** អនុវត្តបានចំនួន ៣៥៧ ១២៣ លានរៀល ស្មើនឹង ១៦២,៦% នៃច្បាប់ហិរញ្ញវត្ថុ, គឺខ្ពស់ជាង ៣,៤ ពិន្ទុភាគរយ ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២១ ដែលអនុវត្តបាន ១៥៩,២% នៃច្បាប់ហិរញ្ញវត្ថុ, ប៉ុន្តែបើគិតចំណូលជាសាច់ប្រាក់ថយចុះ ៩,២% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២១។

• **ចំណូលមិនមែនសារពើពន្ធផ្សេងទៀត ក្រៅពីទ្រព្យសម្បត្តិរដ្ឋ** អនុវត្តបាន ១៩,៧% នៃច្បាប់ហិរញ្ញវត្ថុ, គឺទាបជាងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២១ ដែលអនុវត្តបាន ២៦,១% នៃច្បាប់ហិរញ្ញវត្ថុ, បើគិតចំណូលជាសាច់ប្រាក់មានការថយចុះ ៣២,៣% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២១។

ដោយឡែក ចំណូលកាតព្វកិច្ចពីកាស៊ីណូ និងចំណូលកាតព្វកិច្ចពីឆ្នោត អនុវត្តបានចំនួន ១១ ៣៦៥ លានរៀល ស្មើនឹង ៧,៥% នៃច្បាប់ហិរញ្ញវត្ថុ, គឺខ្ពស់ជាងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២១ ដែលអនុវត្តបាន ១,៧% នៃច្បាប់ហិរញ្ញវត្ថុ, បើគិតជាសាច់ប្រាក់ ចំណូលនេះមានការកើនឡើង ២២៧,១% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២១។ ដូចនេះ តាមការប៉ាន់ស្មានរហូតដល់ដំណាច់ឆ្នាំ ២០២២ ចំណូលកាតព្វកិច្ចពីកាស៊ីណូ និងពីឆ្នោត អាចសម្រេចបានតាមច្បាប់ហិរញ្ញវត្ថុប្រមាណ ១០០,០%។

ជារួម ចំណូលមិនមែនសារពើពន្ធ ដែលមានបីផ្នែកសំខាន់ៗ រួមមាន៖ ចំណូលពីទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធផ្សេងទៀត ក្រៅពីទ្រព្យសម្បត្តិរដ្ឋ ព្រមទាំងចំណូលកាតព្វកិច្ចពីកាស៊ីណូនិងចំណូលកាតព្វកិច្ចពីឆ្នោត ក្នុងឆមាសទី ១ នៅឆ្នាំ ២០២២ អនុវត្តពុំសូវបានល្អ ដោយសារការបន្តរងផលប៉ះពាល់ពីវិបត្តិជំងឺកូវីដ-១៩ ហើយមុខចំណូលខ្លះទៀតកំពុងបំពេញនូវនីតិវិធីកត់ត្រាចូល ដូចជា ចំណូលពីផលទុនរបស់ប្រៃសណីយ៍ និងទូរគមនាគមន៍។ ក៏ប៉ុន្តែតាមការប៉ាន់ស្មាន **រហូតដល់ដំណាច់ឆ្នាំ ២០២២ ចំណូលមិនមែនសារពើពន្ធ អាចនឹងសម្រេចបានប្រមាណដល់ ១០១,១% នៃច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០២២។**

ខ-ចំណូលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

• ចំណូលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងឆមាសទី ១ ឆ្នាំ ២០២២ អនុវត្តបានចំនួន ១ ៦៤១ ០៧៦ លានរៀល ស្មើនឹង ៤៨,៣% នៃច្បាប់ហិរញ្ញវត្ថុ, គឺទាបជាងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២១ ដែលអនុវត្តបាន ៥៥,២% នៃច្បាប់ហិរញ្ញវត្ថុ, បើគិតចំណូលជាសាច់ប្រាក់មានកំណើន ១៥,៣% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២១ ក្នុងនោះ៖

- **ចំណូលសារពើពន្ធ** អនុវត្តបានចំនួន ៧៩៦ ២៧០ លានរៀល ស្មើនឹង ៥០,៣% នៃច្បាប់ហិរញ្ញវត្ថុ ដោយសារការអនុវត្តប្រកបដោយប្រសិទ្ធភាពនូវវិធានការគោលនយោបាយសារពើពន្ធ, វិធានការពង្រឹងរដ្ឋបាលសារពើពន្ធ និងវិធានការអភិបាលកិច្ចល្អ។ បើគិតជាសាច់ប្រាក់មានការកើនឡើង ២១,៤% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២១ ដោយសារការរីករាលដាលនៃជំងឺកូវីដ-១៩។

- **ចំណូលមិនមែនសារពើពន្ធ** អនុវត្តបានចំនួន ១១៨ ១១០ លានរៀល ស្មើនឹង ៤៥,៤% នៃច្បាប់ហិរញ្ញវត្ថុ និង**ចំណូលឧបត្ថម្ភធនពីថវិការដ្ឋ**ចំនួន ៦០៤ ០៤៩ លានរៀល ស្មើនឹង ៤៧,៨% នៃច្បាប់ហិរញ្ញវត្ថុ។

ជារួម ចំណូលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងឆមាសទី ១ ឆ្នាំ ២០២២ នេះ អនុវត្តបានល្អនៅឡើយ និងត្រូវបានប៉ាន់ស្មានថា រហូតដល់ដំណាច់ឆ្នាំ ២០២២ ចំណូលថ្នាក់ក្រោមជាតិអាចនឹងសម្រេចខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុប្រមាណ ១០,៥% ជាពិសេស ចំណូលសារពើពន្ធអាចនឹងសម្រេចបានខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុ ប្រមាណ ២០,៩%។

តារាងទី ៤៖ តារាងចំណូលថវិការដ្ឋបាលថ្នាក់ក្រោមជាតិ					
ប្រតិបត្តិការ	ឆ្នាំ ២០២២				
	ច្បាប់	អនុវត្តឆមាសទី ១		ប៉ាន់ស្មានប្រចាំឆ្នាំ	
	ហិរញ្ញវត្ថុ	ទឹកប្រាក់	%ច្ប.	ទឹកប្រាក់	%ច្ប.
សរុបចំណូលថវិកាថ្នាក់ក្រោមជាតិ	៣ ៣៩៤ ៨១៤	១ ៦៤១ ០៧៦	៤៨,៣%	៣ ៧៥០ ៩៩៦	១១០,៥%
-សរុបចំណូលចរន្ត	៣ ៣៩៤ ៨១៤	១ ៦៤១ ០៧៦	៤៨,៣%	៣ ៧៥០ ៩៩៦	១១០,៥%
ចំណូលសារពើពន្ធ (ប្រមូលដោយអគ្គ.ពន្ធដារ)	១ ៥៨៤ ១២៧	៧៩៦ ២៧០	៥០,៣%	១ ៩១៥ ២២៩	១២០,៩%
ចំណូលមិនមែនសារពើពន្ធ	២៥៩ ៩៨៣	១១៨ ១១០	៤៥,៤%	២៨៥ ០៦៨	១០៩,៦%
ឧបត្ថម្ភថវិកាពីថ្នាក់ជាតិ	១ ២៦៣ ០៥០	៦០៤ ០៤៩	៤៧,៨%	១ ២៦៣ ០៥០	១០០,០%
ចំណូលពីមូលនិធិរដ្ឋបាលថ្នាក់ក្រោមជាតិ	២៨៧ ៦៥៤	១២២ ៦៤៨	៤២,៦%	២៨៧ ៦៥៤	១០០,០%
ក-ចំណូលថវិការាជធានី ខេត្ត	២ ១១៣ ៨៣៣	១ ០៤០ ៥៦៣	៤៩,២%	២ ៤៧០ ០១៥	១១៦,៩%
-ចំណូលចរន្ត	២ ១១៣ ៨៣៣	១ ០៤០ ៥៦៣	៤៩,២%	២ ៤៧០ ០១៥	១១៦,៩%
ចំណូលសារពើពន្ធ (ប្រមូលដោយអគ្គ.ពន្ធដារ)	១ ៥៨៤ ១២៧	៧៩៦ ២៧០	៥០,៣%	១ ៩១៥ ២២៩	១២០,៩%
ចំណូលមិនមែនសារពើពន្ធ	២៤៧ ៧៤៣	១១៦ ២៥៦	៤៦,៩%	២៧២ ៨២៤	១១០,១%
ឧបត្ថម្ភថវិកាពីថ្នាក់ជាតិ	១៣ ៣០៤	៦ ៦៥២	៥០,០%	១៣ ៣០៤	១០០,០%
ចំណូលពីមូលនិធិរដ្ឋបាលថ្នាក់ក្រោមជាតិ	២៦៨ ៦៥៩	១២១ ៣៨៦	៤៥,២%	២៦៨ ៦៥៩	១០០,០%
ខ-ចំណូលថវិការុក្ខ ស្រុក	៤៣៣ ៦២៤	១៧៨ ៦៨២	៤១,២%	៤៣៣ ៦២៤	១០០,០%
-ចំណូលចរន្ត	៤៣៣ ៦២៤	១៧៨ ៦៨២	៤១,២%	៤៣៣ ៦២៤	១០០,០%
ចំណូលមិនមែនសារពើពន្ធ	១២ ២៤០	១ ៨៥៤	១៥,១%	១២ ២៤០	១០០,០%
ឧបត្ថម្ភថវិកាពីថ្នាក់ជាតិ	៤០២ ៣៨៩	១៧៥ ៥៦៦	៤៣,៦%	៤០២ ៣៨៩	១០០,០%
ចំណូលពីមូលនិធិរដ្ឋបាលថ្នាក់ក្រោមជាតិ	១៨ ៩៩៥	១ ២៦២	៦,៦%	១៨ ៩៩៥	១០០,០%
គ-ចំណូលថវិការដ្ឋ សង្កាត់	៨៤៧ ៣៥៧	៤២១ ៨៣១	៤៩,៨%	៨៤៧ ៣៥៧	១០០,០%
-ចំណូលចរន្ត	៨៤៧ ៣៥៧	៤២១ ៨៣១	៤៩,៨%	៨៤៧ ៣៥៧	១០០,០%
ឧបត្ថម្ភថវិកាពីថ្នាក់ជាតិ	៨៤៧ ៣៥៧	៤២១ ៨៣១	៤៩,៨%	៨៤៧ ៣៥៧	១០០,០%

៣.២.២-ការប៉ាន់ស្មាន និងការវាយតម្លៃលើការអនុវត្តចំណូលថវិការដ្ឋឆ្នាំ ២០២២

ជារួម ផ្អែកលើលទ្ធផលសម្រេចបានក្នុងឆមាសទី ១ និងនិន្នាការប្រមូលចំណូលឆមាសទី ២ ខាងមុខនេះ អាចសន្និដ្ឋានបានថា **ការអនុវត្តចំណូលក្នុងប្រទេសទាំងថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ ២០២២ អាចនឹងសម្រេចបានខ្ពស់ជាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២២ ចំនួនប្រមាណ ៦,៦%** ដោយក្នុងនោះ៖

- ចំណូលចរន្តអាចនឹងអនុវត្តសម្រេចខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុប្រមាណ ៤,៧% ដោយសារចំណូលសារពើពន្ធអាចនឹងសម្រេចខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុប្រមាណ ៥,០% ចំណែកឯចំណូលមិនមែនសារពើពន្ធអាចនឹងសម្រេចខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុប្រមាណ ១,៩%,
- ចំណូលមូលធនថវិការដ្ឋ ត្រូវបានប៉ាន់ស្មានថានឹងអាចអនុវត្តបានចំនួន ៣ ២១៣ ៧០៦ លានរៀល គឺខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុប្រមាណ ២៤,៩% ដោយសារការកើនឡើងនៃការទទួលបានមូលនិធិគាំទ្រថវិកា។

ជាមួយនឹងការវាយតម្លៃលើការអនុវត្តចំណូលឆ្នាំ ២០២២ ខាងលើ ផ្នែកចំណូលនេះ នឹងជួបប្រទះ**បញ្ហាប្រឈម និងហានិភ័យ**មួយចំនួន ដូចខាងក្រោម៖

- ការបន្ថយអត្រាពន្ធអាករនាំចូលលើមុខទំនិញមួយចំនួន ដើម្បីជួយជំរុញសហគ្រាសធុនតូចនិងមធ្យម (SMEs) ព្រមទាំងវិស័យអាទិភាពផ្សេងទៀត ;
- ការលើកទឹកចិត្តពន្ធនិងអាករក្នុងគោលដៅទាក់ទាញការវិនិយោគ;
- ការអនុវត្តអត្រាពន្ធគយអនុគ្រោះក្រោមកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីនានា;
- កំណើនផលិតផលក្នុងស្រុកមួយចំនួនជំនួសការនាំចូល ជាពិសេសការកើនឡើងនៃវិនិយោគផ្តុំដំឡើងរថយន្តក្នុងប្រទេស;
- កំណើនការប្រើប្រាស់ថាមពលពីប្រភពមិនមែនប្រេង;
- ការថយចុះនៃចំណូលពីរថយន្តគ្មានពន្ធមានស្រាប់ក្នុងប្រទេស;
- វិប្បធម៌សារពើពន្ធនៅមានកម្រិតនៅឡើយ;
- និន្នាការកើនឡើងនៃការធ្វើពាណិជ្ជកម្មអេឡិចត្រូនិក (e-Commerce) ដែលអាចបង្កជាហានិភ័យលើការគ្រប់គ្រងការងារប្រមូលចំណូល និងសុវត្ថិភាពសង្គម;
- ឥទ្ធិពលនៃវិបត្តិជំងឺកូវីដ-១៩ ជាសកល នៅតែបន្តមានផលប៉ះពាល់លើសេដ្ឋកិច្ចកម្ពុជា;
- សង្គ្រាមនៅប្រទេសអ៊ុយក្រែន និងភាពតានតឹងខាងភូមិសាស្ត្រនយោបាយបានធ្វើឱ្យប៉ះពាល់ដល់សេដ្ឋកិច្ចជាសកល;
- ការកើនឡើងនូវតម្លៃប្រេង និងម្ហូបអាហារ នាំឱ្យកើនឡើងនូវអត្រាអតិផរណា ចំណូលរបស់ប្រជាជនធ្លាក់ចុះ និងកម្លាំងទិញធ្លាក់ចុះ;
- ការថមថយកំណើនសេដ្ឋកិច្ចសកល;
- ការបន្តប្រកាន់យកគោលនយោបាយគាំពារនិយម និងសង្គ្រាមពាណិជ្ជកម្មរវាងប្រទេសមហាអំណាចសេដ្ឋកិច្ច;
- កំណើននៃការធ្វើអាជីវកម្មតាមអនឡាញ ពិសេសក្នុងបរិការណ៍កូវីដ-១៩ ដែលក្នុងនោះមួយចំនួនធំមិនមានចុះបញ្ជីត្រឹមត្រូវនោះទេ ហើយក៏ជាច្រកគេចវេះការប្រកាសបង់ពន្ធខណៈដែលកម្ពុជាពុំទាន់មានលទ្ធភាពដំណើរការច្រកទ្វារអ៊ីនធឺណិតជាតិ (National Internet Gateway) និងច្រកចេញ-ចូលប្រព័ន្ធទូទាត់សងប្រាក់ជាតិ (National Payment Gateway);
- សេដ្ឋកិច្ចស្រមោល (Shadow Economy) ដែលកើតមានក្នុងវិស័យសំខាន់ជាច្រើនរួមមានវិស័យសាងសង់, វិស័យសហគ្រាសធុនតូច និងមធ្យម (SMEs), វិស័យធនធានធម្មជាតិ;
- ការធ្វើបច្ចុប្បន្នភាពច្បាប់ និងបទប្បញ្ញត្តិស្តីពីពន្ធជារមួយចំនួននៅមិនទាន់ឆ្លើយតបនឹងការវិវត្តទៅមុខនៃបរិបទសេដ្ឋកិច្ចកម្ពុជា;
- ការកើនឡើងថ្លៃវត្ថុធាតុដើមដោយសារចរន្តទីផ្សារតំបន់ និងសាកល ដែលជះឥទ្ធិពលជារួមដល់ផលិតភាពនិងជារួមអាចធ្វើឱ្យមានការថមថយចំណូល;
- អ្នកជាប់ពន្ធមួយចំនួននៅតែមិនទាន់អនុវត្តកាតព្វកិច្ចក្នុងការចុះបញ្ជីពន្ធជារបស់ខ្លួនឱ្យបានត្រឹមត្រូវនៅឡើយ និងមានការក្លែងបន្លំឈរឈ្មោះជំនួសឱ្យក្រុមហ៊ុន ឬការប្រើប្រាស់ព័ត៌មានមិនពិតក្នុងការ

ចុះបញ្ជី, ការបង្កើតសហគ្រាសសិប្បនិម្មិតដើម្បីគេចវេះពន្ធ និងការមិនសហការផ្តល់ឯកសារចុះបញ្ជីឱ្យបានគ្រប់គ្រាន់ ឬមិនមកធ្វើបច្ចុប្បន្នភាពព័ត៌មានសហគ្រាស;

• ការរួញរាក្នុងការចូលរួមអនុវត្តកាតព្វកិច្ចពន្ធលើចំណេញមូលធន (CGT) ពីសំណាក់វិស័យឯកជន បើទោះជាពន្ធនេះត្រូវបានច្បាប់អនុញ្ញាតឱ្យប្រមូលជាយូរណាស់មកហើយ និងមានការផ្សព្វផ្សាយទូលំទូលាយយ៉ាងណាក្តី;

• ហេដ្ឋារចនាសម្ព័ន្ធសម្រាប់បម្រើការក្នុងវិស័យទូរគមនាគមន៍ (Telecommunication) និងការផ្តល់សេវាអ៊ីនធឺណិត នៅមានកម្រិតនៅឡើយពុំទាន់ឆ្លើយតបតាមតម្រូវការកើនឡើងសម្រាប់ការប្រើប្រាស់ប្រព័ន្ធ និងកម្មវិធីផ្សេងៗជូនអ្នកជាប់ពន្ធ និងការគ្រប់គ្រងរដ្ឋបាលសារពើពន្ធឱ្យបានល្អប្រសើរ;

• មុខសញ្ញាចំណូលសំខាន់ៗធ្លាក់ចុះដោយសារវិបត្តិនៃជំងឺកូវីដ-១៩ និងប្រមូលមិនទាន់អស់លទ្ធភាព;

• កង្វះការសិក្សាអំពីលទ្ធភាពក្នុងការស្វែងរកប្រភពចំណូលថ្មី;

• សមត្ថភាពមន្ត្រី និងប្រសិទ្ធភាពស្ថាប័ន នៅមានកម្រិត;

• ត្រូវការពេលវេលាមួយសមស្របដើម្បីធ្វើការកែទម្រង់ការប្រមូលចំណូលលើវិស័យទូរគមនាគមន៍ ធនធានរ៉ែ និងសម្បទានដីសេដ្ឋកិច្ច;

• កង្វះយន្តការផ្ទៀងផ្ទាត់ ក្នុងការប្រមូលចំណូល ពីក្រសួង-ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ;

• ភាពខ្វះចន្លោះនៃបទប្បញ្ញត្តិគាំទ្រ និងប្រព័ន្ធគ្រប់គ្រង ទិន្នន័យចំណូលមិនមែនសារពើពន្ធ;

• ភាពមិនទាន់បានយកចិត្តទុកដាក់ខ្ពស់ពីក្រសួង ស្ថាប័នពាក់ព័ន្ធ ក្នុងការកែលម្អតាមវិធានការរបស់អធិការកិច្ច និងអនុសាសន៍របស់សវនកម្មលើការងារគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និង

• អាជីវកម្មកាស៊ីណូនៅតាមព្រំដែនមានស្ថានភាពបើក-បិទមិនទៀងទាត់។

៣.២.៣-ការអនុវត្តចំណាយឆមាសទី ១ ឆ្នាំ ២០២២

ក-ចំណាយថ្នាក់ជាតិ

ក.១-**ចំណាយសរុបឆ្លងកាត់អគ្គនាយកដ្ឋានរតនាគារជាតិ** ប្រចាំឆមាសទី ១ ឆ្នាំ ២០២២ តាមអាណត្តិបើកប្រាក់ (**មិនទាន់គិតបុរេប្រទាន**) អនុវត្តបានចំនួន ១១ ១២៦ ២០៤ លានរៀល ស្មើនឹង ៤១,៦% នៃច្បាប់ហិរញ្ញវត្ថុ គឺទាបជាងធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២១ ដែលអនុវត្តបាន ៤៣,១% នៃច្បាប់ហិរញ្ញវត្ថុ, បើគិតចំណាយជាសាច់ប្រាក់កើនឡើង ៣,២% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២១ ដែលក្នុងនោះ **ចំណាយចរន្ត** អនុវត្តបានចំនួន ៧ ៩០២ ១៨២ លានរៀល ស្មើនឹង ៤១,៣% នៃច្បាប់ហិរញ្ញវត្ថុ គឺមានល្បឿនយឺតជាងនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២១ ដែលអនុវត្តបាន ៤៤,៣% នៃច្បាប់ហិរញ្ញវត្ថុ, បើគិតចំណាយជាសាច់ប្រាក់កើនឡើង ២,៣% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២១។ **ចំណាយមូលធន** អនុវត្តបានចំនួន ៣ ២២៤ ០២២ លានរៀល ស្មើនឹង ៤២,១% នៃច្បាប់ហិរញ្ញវត្ថុ គឺមានសម្ទុះលឿនជាងចំនួន ១,៨ ពិន្ទុភាគរយ ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២១ ដែលអនុវត្តបាន ៤០,៣% នៃច្បាប់ហិរញ្ញវត្ថុ, បើគិតចំណាយជាសាច់ប្រាក់កើនឡើង ៥,៦% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២១។ ***បើគិតទាំងចំណាយតាមបុរេប្រទាន** ដែលមានចំនួនប្រមាណ ២៥៧ ៤៩១ លានរៀល (ចំណាយចរន្ត និងចំណាយមូលធន) ចំណាយសរុបឆ្លងកាត់អគ្គនាយកដ្ឋានរតនាគារជាតិ ប្រចាំឆមាសទី ១ ឆ្នាំ ២០២២ អនុវត្តបាន*

១១ ៣៨៣ ៦៩៥ លានរៀល ស្មើនឹង ៤២,៥% នៃច្បាប់ហិរញ្ញវត្ថុ ក្នុងនោះចំណាយចរន្តអនុវត្តបាន ៤២,៥% នៃច្បាប់ហិរញ្ញវត្ថុ និងចំណាយមូលធនអនុវត្តបាន ៤២,៧% នៃច្បាប់ហិរញ្ញវត្ថុ។

ឯកតា៖ លានរៀល

តារាងទី ៥៖ តារាងចំណាយថវិការដ្ឋឆ្លងកាត់អគ្គនាយកដ្ឋានរតនាគារជាតិ					
ប្រតិបត្តិការ	ឆ្នាំ ២០២២				
	ច្បាប់ហិរញ្ញវត្ថុ	អនុវត្តឆមាសទី ១		ប៉ាន់ស្មានប្រចាំឆ្នាំ	
		ទឹកប្រាក់	%ច្ប.	ទឹកប្រាក់	%ច្ប.
II. ចំណាយឆ្លងកាត់អគ្គនាយកដ្ឋានរតនាគារជាតិ	២៦ ៧៦៣ ៣៨២	១១ ៣៨៣ ៦៩៥	៤២,៥%	២៦ ៤៤០ ៥៧៤	៩៨,៨%
១. ចំណាយចរន្ត	១៩ ១១១ ៧០៤	៨ ១១៥ ៧៨៣	៤២,៥%	១៨ ៧៩៤ ៤៥៩	៩៨,៣%
+តាមអាណត្តិបើកប្រាក់	១៩ ១១១ ៧០៤	៧ ៩០២ ១៨២		១៨ ៧៩៤ ៤៥៩	
+តាមរដ្ឋទេយ្យបុរេប្រទាន និងបុរេប្រទាន		២១៣ ៦០១			
២. ចំណាយមូលធន	៧ ៦៥១ ៦៧៨	៣ ២៦៧ ៩១២	៤២,៧%	៧ ៦៤៦ ១១៥	៩៩,៩%
+តាមអាណត្តិបើកប្រាក់	៧ ៦៥១ ៦៧៨	៣ ២២៤ ០២២		៧ ៦៤៦ ១១៥	
+តាមបុរេប្រទាន		៤៣ ៨៩០			

ក.២-ចំណាយចរន្តសរុបតាមអាណត្តិបើកប្រាក់សម្រាប់ឆមាសទី ១ ឆ្នាំ ២០២២ អនុវត្តបាន ៤១,៦% នៃច្បាប់ហិរញ្ញវត្ថុ គឺមានសម្នុះយឺតជាង ២,៧ ពិន្ទុភាគរយ ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២១ ដែលអនុវត្តបាន ៤៤,៣% នៃច្បាប់ហិរញ្ញវត្ថុ ក្នុងនោះ៖

-**ចំណាយបន្ទុកបុគ្គលិក** ដែលមានសមាមាត្រ ៤៥,៣% នៃចំណាយចរន្តថ្នាក់ជាតិសរុប អនុវត្តបានតែ ៤ ០១៥ ៥០៥ លានរៀល ស្មើនឹង ៤៦,៤% នៃច្បាប់ហិរញ្ញវត្ថុ គឺមានសម្នុះយឺតជាង ០,៣ ពិន្ទុភាគរយ ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២១ ដែលអនុវត្តបាន ៤៦,៧% នៃច្បាប់ហិរញ្ញវត្ថុ, បើគិតចំណាយជាសាច់ប្រាក់កើនឡើង ០,៤% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២១។ ជារួម ចំណាយបន្ទុកបុគ្គលិកមានសម្នុះយឺត ដោយសារក្រសួង-ស្ថាប័នភាគច្រើននៅមិនទាន់លើកសំណើសុំទូទាត់ប្រាក់រង្វាន់។ ចំពោះប្រាក់បៀវត្សរបស់មន្ត្រីរាជការ គឺអនុវត្តបានល្អប្រសើរដោយសារការបើកបៀវត្សប្រចាំខែបានប្រព្រឹត្តទៅរលូន និងទៀងទាត់ចំនួន ២ ដងក្នុងមួយខែ នៃខែនីមួយៗ តាមប្រព័ន្ធធនាគារ។

-**ចំណាយមិនមែនបន្ទុកបុគ្គលិក** ដែលមានសមាមាត្រ ៥៤,៧% នៃចំណាយចរន្តថ្នាក់ជាតិសរុប អនុវត្តបានចំនួន ៣ ៨៨៦ ៦៧៧ លានរៀល ស្មើនឹង ៣៧,២% នៃច្បាប់ហិរញ្ញវត្ថុ គឺមានសម្នុះយឺតជាងចំនួន ៤,៨ ពិន្ទុភាគរយ ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២១ ដែលអនុវត្តបាន ៤២,០% នៃច្បាប់ហិរញ្ញវត្ថុ, បើគិតចំណាយជាសាច់ប្រាក់កើនឡើង ៤,២% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២១ ដោយសារចំណាយកិច្ចលទ្ធកម្មមួយចំនួនដែលមានផែនការលើសពី ១ ០០០ លានរៀល ត្រូវបានផ្តល់ជានាចំណាយជូនត្រឹម ៥០% សិន សម្រាប់ការអនុវត្តក្នុងឆមាសទី ១ និង ទំហំនៅសល់ ៥០% ទៀត ត្រៀមទុកផ្តល់បន្ថែមសម្រាប់ការអនុវត្តក្នុងឆមាសទី ២ ឆ្នាំ ២០២២។

ក.៣-**ពិនិត្យមើលការអនុវត្តចំណាយចរន្តតាមវិស័យ**, តាមអាណត្តិបើកប្រាក់, យើញថា៖

- **វិស័យរដ្ឋបាលទូទៅ** អនុវត្តបានចំនួន ៨២៣ ៣៧៦ លានរៀល ស្មើនឹង ៤៣,០% នៃច្បាប់ហិរញ្ញវត្ថុ គឺមានសម្ទុះយឺតជាង ៥,១ ពិន្ទុភាគរយ ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២១ ដែលអនុវត្តបាន ៤៨,១% នៃច្បាប់ហិរញ្ញវត្ថុ, បើគិតចំណាយជាសាច់ប្រាក់ថយចុះ ៥,៨% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២១។ ក្នុងនោះ **ចំណាយបន្ទុកបុគ្គលិក** អនុវត្តបានចំនួន ៣១៦ ២៨២ លានរៀល ស្មើនឹង ៤៥,៦% នៃច្បាប់ហិរញ្ញវត្ថុ គឺមានសម្ទុះយឺតជាង ២,០ ពិន្ទុភាគរយ ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២១ ដែលអនុវត្តបាន ៤៧,៦% នៃច្បាប់ហិរញ្ញវត្ថុ, បើគិតចំណាយជាសាច់ប្រាក់ គឺថយចុះ ៤,១% ធៀបនឹងរយៈពេលដូចគ្នា ក្នុងឆ្នាំ ២០២១ ដោយសារក្រសួង-ស្ថាប័នមួយចំនួននៃវិស័យនេះនៅមិនទាន់លើកសំណើសុំទូទាត់ប្រាក់រង្វាន់។ **ចំណាយមិនមែនបន្ទុកបុគ្គលិក** អនុវត្តបាន ៥០៧ ០៩៤ លានរៀល ស្មើនឹង ៤១,៥% នៃច្បាប់ហិរញ្ញវត្ថុ គឺមានសម្ទុះយឺតជាង ៧,០ ពិន្ទុភាគរយ ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២១ ដែលអនុវត្តបាន ៤៨,៥% នៃច្បាប់ហិរញ្ញវត្ថុ ដោយសារចំណាយកិច្ចលទ្ធកម្មមួយចំនួនដែលមានតណាទានថវិកាធំជាង ១ ០០០ លានរៀល ត្រូវបានផ្តល់ធានាចំណាយជូនត្រឹម ៥០% សិន សម្រាប់ការអនុវត្តក្នុងឆមាសទី ១ ឆ្នាំ ២០២២ និងទំហំនៅសល់ ៥០% ទៀត ត្រៀមទុកផ្តល់បន្ថែមសម្រាប់ការអនុវត្តក្នុងឆមាសទី ២ ឆ្នាំ ២០២២ នេះ។

ជារួម តណាទានថវិការបស់ក្រសួង-ស្ថាប័ននៃវិស័យរដ្ឋបាលទូទៅ ត្រូវបានផ្តោតលើការអនុវត្តសកម្មភាពអាទិភាពសំខាន់ៗ រួមមាន៖ (១)-លើកកម្ពស់ប្រសិទ្ធភាពការងារគ្រប់គ្រងចំណូល និងប្រមូលចំណូលសារពើពន្ធ, (២)-គាំទ្រការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ, (៣)-គាំទ្រការកែទម្រង់វិស័យដីធ្លី, (៤)-គាំទ្រ និងពង្រឹងគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម, (៥)-គាំទ្រដល់ការប្រយុទ្ធប្រឆាំងអំពើពុករលួយ, (៦)-បង្កើនប្រសិទ្ធភាពនៃកិច្ចការទូត និង (៧)-គាំទ្រដល់ការរៀបចំបោះឆ្នោតឃុំ-សង្កាត់ឆ្នាំ ២០២២។

- **វិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ** អនុវត្តបានចំនួន ២ ០៥៨ ២៨៤ លានរៀល ស្មើនឹង ៤៤,០% នៃច្បាប់ហិរញ្ញវត្ថុ គឺមានសម្ទុះលឿនជាង ០,៤ ពិន្ទុភាគរយ ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២១ ដែលអនុវត្តបាន ៤៣,៦% នៃច្បាប់ហិរញ្ញវត្ថុ, បើគិតចំណាយជាសាច់ប្រាក់កើនឡើង ០,២%។ ក្នុងនោះ **ចំណាយបន្ទុកបុគ្គលិក** អនុវត្តបានចំនួន ១ ៨៤៥ ៣១០ លានរៀល ស្មើនឹង ៤៨,៣% នៃច្បាប់ហិរញ្ញវត្ថុ គឺមានសម្ទុះលឿនជាងបន្តិចនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២១ ដែលអនុវត្តបាន ៤៨,១% នៃច្បាប់ហិរញ្ញវត្ថុ, បើគិតចំណាយជាសាច់ប្រាក់កើនឡើង ០,២% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២១ ដោយសារមានការបើកផ្តល់ប្រាក់ឧបត្ថម្ភគោលនយោបាយមួយលើកដំបូងជូនគ្រួសារមន្ត្រីនគរបាលចូលនិវត្តន៍ចំនួន ១ ០៣៥ នាក់ និងឧបត្ថម្ភគោលនយោបាយមួយលើកដំបូង ជូនគ្រួសារមន្ត្រីនគរបាលពលី-មរណៈ ចំនួន ១៩០ នាក់ និង **ចំណាយមិនមែនបន្ទុកបុគ្គលិក** អនុវត្តបានចំនួន ២១២ ៩៧៣ លានរៀល ស្មើនឹង ២៥,០% នៃច្បាប់ហិរញ្ញវត្ថុ គឺមានសម្ទុះលឿនជាងចំនួន ០,៩ ពិន្ទុភាគរយ ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២១ ដែលអនុវត្តបាន ២៤,១% នៃច្បាប់ហិរញ្ញវត្ថុ, បើគិតចំណាយជាសាច់ប្រាក់កើនឡើង ០,២% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២១ ដោយសារ, ម្យ៉ាង, ការងារចំណាយមួយចំនួនត្រូវបានផ្អាក ឬលុបចោល ពិសេសមុខចំណាយទិញសម្ភារការពារជំងឺកូវីដ-១៩ ជាដើម និង ម្យ៉ាងទៀត, ចំណាយកិច្ចលទ្ធកម្មមួយចំនួនដែលមានតណាទានថវិកា

ធំជាង ១ ០០០ លានរៀល ត្រូវបានផ្តល់ជានាចំណាយជូនត្រឹម ៥០% សិន សម្រាប់ការអនុវត្តក្នុងឆមាសទី ១ និងទំហំនៅសល់ ៥០% ទៀត ត្រៀមទុកផ្តល់បន្ថែមសម្រាប់ការអនុវត្តក្នុងឆមាសទី ២ ឆ្នាំ ២០២២ នេះ។

ជារួម ឥណទានថវិការបស់ក្រសួង-ស្ថាប័ននៃវិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ ត្រូវបានផ្តោតលើការអនុវត្តសកម្មភាពអាទិភាពសំខាន់ៗ រួមមាន៖ (១)-គាំទ្រដល់ការពង្រឹងសមត្ថភាពរបស់នគរបាល និងកងកម្លាំងប្រដាប់អាវុធ, (២)-បន្តផ្តោតការយកចិត្តទុកដាក់លើជីវភាព និងសុខុមាលភាពកងកម្លាំងប្រដាប់អាវុធ, (៣)-បង្កើនការគាំទ្រដល់កិច្ចដំណើរការរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម សាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ និងរដ្ឋបាលតុលាការ, (៤)-គាំទ្រកិច្ចដំណើរការរដ្ឋបាល និងអន្តរាគមន៍ផ្សេងៗ, (៥)-គាំទ្រដល់ដំណើរការនៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ, (៦)-គាំទ្រការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព, (៧)-គាំទ្រដល់ការរៀបចំប្រព័ន្ធត្រួតពិនិត្យសន្តិសុខតាមច្រកព្រំដែន និងការផលិតលិខិតឆ្លងដែន, (៨)-បន្តគាំទ្រដល់ការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ស្ត្រី និងកុមារ, (៩)-បន្តគាំទ្រដល់ការប្រយុទ្ធប្រឆាំងគ្រឿងញៀន និង (១០)-បន្តគាំទ្រសេវាឥតគិតថ្លៃរបស់គណៈមេធាវីកម្ពុជា។

- **វិស័យសង្គមកិច្ច** អនុវត្តបានចំនួន ៣ ១៤៦ ២១០ លានរៀល (តាមអាណត្តិបើកប្រាក់) ស្មើនឹង ៤២,៩% នៃច្បាប់ហិរញ្ញវត្ថុ គឺមានសម្ទុះយឺតជាង ២,៦ ពិន្ទុភាគរយ ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២១, បើគិតចំណាយជាសាច់ប្រាក់កើនឡើង ០,៦% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២១។ **ចំណាយបន្ទុកបុគ្គលិក** អនុវត្តបានចំនួន ១ ៦៣៧ ០៩២ លានរៀល (តាមអាណត្តិបើកប្រាក់) ស្មើនឹង ៤៥,៣% នៃច្បាប់ហិរញ្ញវត្ថុ គឺមានសម្ទុះយឺតបន្តិចធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២១ ដែលអនុវត្តបាន ៤៦,០% នៃច្បាប់ហិរញ្ញវត្ថុ ដោយសារក្រសួងមួយចំនួននៅមិនទាន់ទូទាត់ប្រាក់រង្វាន់នៅឡើយ។ ចំពោះ**ចំណាយមិនមែនបន្ទុកបុគ្គលិក** អនុវត្តបានចំនួន ៤០,៦% នៃច្បាប់ហិរញ្ញវត្ថុ គឺមានសម្ទុះយឺតជាង ៤,៥ ពិន្ទុភាគរយ ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២១ ដែលអនុវត្តបាន ៤៥,១% នៃច្បាប់ហិរញ្ញវត្ថុ ដោយសារក្រសួងសុខាភិបាលបានកាត់បន្ថយចំណាយជាច្រើនលើមុខចំណាយដោះស្រាយជំងឺកូវីដ-១៩។

ជារួម ឥណទានថវិការបស់ក្រសួង-ស្ថាប័ននៃវិស័យសង្គមកិច្ច ត្រូវបានផ្តោតលើការអនុវត្តសកម្មភាពអាទិភាពសំខាន់ៗ រួមមាន៖ (១)-**បន្តគាំទ្រការប្រយុទ្ធនឹងជំងឺកូវីដ-១៩**, (២)-លើកកម្ពស់គុណភាព និងការទទួលបានសេវាសុខាភិបាល, (៣)-ពង្រឹងគុណភាព និងគាំទ្រសេវាអប់រំ, (៤)-លើកកម្ពស់វិស័យកីឬាជាតិ, (៥)-អភិវឌ្ឍជំនាញ និងវិស័យការងារ, (៦)-ទប់ស្កាត់អំពើហិង្សាលើស្ត្រី និងកុមារ, (៧)-ឧបត្ថម្ភគាំទ្រដល់សមាគមអតីតយុទ្ធជន, (៨)-បង្កើនការឧបត្ថម្ភដល់មជ្ឈមណ្ឌលស្តារនីតិសម្បទា តាមបណ្តារាជធានី-ខេត្ត និង ការឧបត្ថម្ភគាំទ្រមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្ម កាយសម្បទា, (៩)-ផ្តល់ថវិកាគាំទ្រដល់ការដោះស្រាយជីវភាព ចំពោះជនក្រីក្រនិងចាស់ជរានៅតាមសហគមន៍, (១០)-គាំទ្រដល់ការប្រយុទ្ធប្រឆាំងព័ត៌មានក្លែងក្លាយ, (១១)-ការពារ និងអភិរក្សធនធានធម្មជាតិ, (១២)-អភិរក្ស និងអភិវឌ្ឍវប្បធម៌ជាតិ, (១៣)-សុខដុមនីយកម្មសាសនា។

- **វិស័យសេដ្ឋកិច្ច** អនុវត្តបានចំនួន ៤០៨ ០០១ លានរៀល ស្មើនឹង ២៨,០% នៃច្បាប់ហិរញ្ញវត្ថុ គឺមានសម្ទុះលឿនជាងចំនួន ៤,២ ពិន្ទុភាគរយ ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២១ ដែលអនុវត្តបាន

២៣,៨% នៃច្បាប់ហិរញ្ញវត្ថុ, បើគិតចំណាយជាសាច់ប្រាក់កើនឡើង ១៧,៦%។ ក្នុងនោះ **ចំណាយបន្ទុកបុគ្គលិក** អនុវត្តបានចំនួន ២១៦ ៨២០ លានរៀល ស្មើនឹង ៤១,២% នៃច្បាប់ហិរញ្ញវត្ថុ គឺមានសម្ទុះលឿនជាង ១,១ ពិន្ទុភាគរយ ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២១ ដែលអនុវត្តបាន ៤០,១% នៃច្បាប់ហិរញ្ញវត្ថុ, បើគិតចំណាយជាសាច់ប្រាក់កើនឡើង ៤,៥%។ **ចំណាយមិនមែនបន្ទុកបុគ្គលិក** អនុវត្តបានចំនួន ១៩១ ១៨១ លានរៀល ស្មើនឹង ២០,៥% នៃច្បាប់ហិរញ្ញវត្ថុ គឺមានសម្ទុះលឿនជាង ៥,៧ ពិន្ទុភាគរយ ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២១ ដែលអនុវត្តបាន ១៤,៨% នៃច្បាប់ហិរញ្ញវត្ថុ ដោយសារការរីករាលដាលជំងឺកូវីដ-១៩ បានស្រាកស្រាន្ត ធ្វើឱ្យអាចដំណើរការជោគជ័យតាឡើងវិញនូវការអនុវត្តសកម្មភាពពាក់ព័ន្ធនឹងការរៀបចំពិព័ណ៌ក្នុង និងក្រៅប្រទេស ។

ជារួម ឥណទានថវិការបស់ក្រសួង-ស្ថាប័ននៃវិស័យសេដ្ឋកិច្ចនេះ ត្រូវបានផ្តោតទៅលើការអនុវត្តសកម្មភាពអាទិភាពសំខាន់ៗ រួមមាន៖ (១)-បន្តការលើកកម្ពស់បច្ចេកទេសកសិកម្ម និងសុវត្ថិភាពចំណីអាហារ, (២)-ពង្រឹងការគ្រប់គ្រងដីសម្បទានសេដ្ឋកិច្ច និងការបង្ការ ទប់ស្កាត់ និងបង្ក្រាបបទល្មើសព្រៃឈើ និងជលផល, (៣)-បង្កើនការគាំទ្រដល់ការពង្រឹងប្រសិទ្ធភាពក្នុងការគ្រប់គ្រងធនធានរ៉ែគ្រប់ប្រភេទ, (៤)-ជំរុញការអភិវឌ្ឍទឹកស្អាត និងអនាម័យជនបទ, (៥)-ជួសជុល និងថែទាំប្រព័ន្ធធារាសាស្ត្រ, (៦)-ជំរុញការអភិវឌ្ឍផលិតផល និងការពង្រឹងគុណភាពសេវាទេសចរណ៍, (៧)-បន្តបើកទីផ្សារសម្រាប់ការនាំចេញរបស់កម្ពុជា, (៨)-បន្តជួសជុល ថែទាំផ្លូវ ស្ពាន និងផ្លូវលំជនបទ ព្រមទាំងការស្តារស្រះ ជីកស្រះ និងអណ្តូងទឹក ដើម្បីទប់ទល់នឹងគ្រោះរាំងស្ងួត, (៩)-ត្រួតពិនិត្យសុវត្ថិភាពចំណីអាហារ, (១០)-អភិវឌ្ឍប្រព័ន្ធរដ្ឋបាលអេឡិចត្រូនិក, (១១)-គាំទ្រដល់ការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម, និង (១២)-អភិវឌ្ឍប្រព័ន្ធស្តង់ដា និងមាត្រាសាស្ត្រ។

ដូច្នេះ បើធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២១, ក្នុងរយៈពេល ៦ ខែដើមឆ្នាំ ២០២២ នេះ, ការអនុវត្តចំណាយនៃវិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ មានសម្ទុះលឿនជាង ដោយសារការអនុវត្តចំណាយបន្ទុកបុគ្គលិកមានសម្ទុះលឿន ព្រោះមានការបើកផ្តល់ប្រាក់ឧបត្ថម្ភគោលនយោបាយមួយលើកដំបូងជូនគ្រួសារមន្ត្រីនគរបាលចូលនិវត្តន៍ និងឧបត្ថម្ភប្រាក់គោលនយោបាយមួយលើកដំបូងជូនគ្រួសារមន្ត្រីនគរបាលពលី-មរណៈ។ ចំពោះការអនុវត្តចំណាយនៃវិស័យសេដ្ឋកិច្ច ក៏មានសម្ទុះលឿនផងដែរ ដោយសារការរីករាលដាលជំងឺកូវីដ-១៩ បានស្រាកស្រាន្ត នាំឱ្យអាចដំណើរការធម្មតាឡើងវិញនូវសកម្មភាពពាក់ព័ន្ធនឹងការរៀបចំពិព័ណ៌ក្នុង និងក្រៅប្រទេស។ ចំណែកឯ ការអនុវត្តចំណាយនៃវិស័យរដ្ឋបាលទូទៅ និងវិស័យសង្គមកិច្ចមានសម្ទុះយឺតជាងបន្តិច ដោយសារការទូទាត់ប្រាក់ឯកជនអនុវត្តបានតិចតួច ហើយម្យ៉ាងទៀត ចំណាយកិច្ចលទ្ធកម្មដែលមានឥណទានថវិកាធំជាង ១ ០០០ លានរៀល ត្រូវបានផ្តល់ធានាចំណាយជូនត្រឹម ៥០% សិនសម្រាប់ការអនុវត្តក្នុងឆមាសទី ១ និងទំហំនៅសល់ ៥០% ទៀត នឹងផ្តល់បន្ថែមសម្រាប់ការអនុវត្តក្នុងឆមាសទី ២ ឆ្នាំ ២០២២ ដែលជាវិធានការតឹងតឹងលើមុខចំណាយខ្លះ ដើម្បីត្រៀមសន្សំចំណាយសម្រាប់ទប់ទល់នឹងការធ្លាក់ចុះនូវការប្រមូលចំណូល។

ក.៤-ចំណាយមូលធន សរុបសម្រាប់ឆមាសទី ១ ឆ្នាំ ២០២២ តាមអាណត្តិបើកប្រាក់អនុវត្តបាន ៤២,១% នៃច្បាប់ហិរញ្ញវត្ថុ គឺមានសម្ទុះលឿនជាង ១,៨ ពិន្ទុភាគរយ ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២១

ដែលអនុវត្តបាន ៤០,៣% នៃច្បាប់ហិរញ្ញវត្ថុ, បើគិតចំណាយជាសាច់ប្រាក់កើនឡើង ៥,៦% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២១។ លទ្ធផលនៃការអនុវត្តនេះ រួមមាន **ចំណាយវិនិយោគដោយហិរញ្ញប្បទានក្នុងប្រទេស** អនុវត្តបានចំនួន ២ ៥៨៩ ៤៤៩ លានរៀល ស្មើនឹង ៤១,៩% នៃច្បាប់ហិរញ្ញវត្ថុ មានសម្លុះលឿនជាង ៣,៥ ពិន្ទុភាគរយ ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២១ ដែលអនុវត្តបាន ៣៨,៤% នៃច្បាប់ហិរញ្ញវត្ថុ។ បើគិតទាំងបុរេប្រទានចំណាយមូលធនអនុវត្តបាន ៤២,៧% នៃច្បាប់ហិរញ្ញវត្ថុ គឺមានសម្លុះលឿនជាង ២,៤ ពិន្ទុភាគរយ ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២១ ដែលអនុវត្តបាន ៤០,៣% នៃច្បាប់ហិរញ្ញវត្ថុ, បើគិតចំណាយជាសាច់ប្រាក់កើនឡើង ៧% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២១។ ដោយឡែក **ចំណាយមូលនិធិទ្រទ្រង់ថវិកា** អនុវត្តបានចំនួន **១២២ ៣២៥ លានរៀល ស្មើនឹង ៩,៦% នៃច្បាប់ហិរញ្ញវត្ថុ គឺមានសម្លុះយឺតជាង ៣៩,២** ពិន្ទុភាគរយ ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២១ ដែលអនុវត្តបាន ៤៨,៨% នៃច្បាប់ហិរញ្ញវត្ថុ។ **ចំណាយលើការទូទាត់ប្រាក់ខ្វី** អនុវត្តបានចំនួន ៦៣៤ ៥៧៣ លានរៀល ស្មើនឹង ៤២,៩% នៃច្បាប់ហិរញ្ញវត្ថុ ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២១ គឺមានសម្លុះយឺតជាង ៧,៤ ពិន្ទុភាគរយ។ **តាមការព្យាករណ៍រហូតដល់ចុងឆ្នាំ ចំណាយមូលធនដោយថវិកាជាតិ អាចនឹងសម្រេចបានប្រមាណ ១០០% នៃច្បាប់ហិរញ្ញវត្ថុ។** ចំពោះចំណាយវិនិយោគដោយហិរញ្ញប្បទានក្រៅប្រទេសនឹងជម្រាបជូនក្នុងផ្នែក ៣.២.៤ ខាងក្រោម ព្រោះស្ថានភាពចំណាយវិនិយោគដោយហិរញ្ញប្បទានក្រៅប្រទេស ជាគោលការណ៍គឺស្មើនឹងចំណូលវិនិយោគដោយហិរញ្ញប្បទានក្រៅប្រទេស ហើយជាប្រភេទចំណូល-ចំណាយប្រតិបត្តិការក្រៅប្រព័ន្ធធនាគារជាតិ។

ខ-ចំណាយថ្នាក់ក្រោមជាតិ

ចំណាយថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងឆមាសទី ១ ឆ្នាំ ២០២២ អនុវត្តបានចំនួន ១ ១៩៣ ៧១៨ លានរៀល ស្មើនឹង ៣៥,២% នៃច្បាប់ហិរញ្ញវត្ថុ គឺមានសម្លុះយឺតជាង ០,៧ ពិន្ទុភាគរយ ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២១ ដែលអនុវត្តបាន ៣៥,៩% នៃច្បាប់ហិរញ្ញវត្ថុ, បើគិតចំណាយជាសាច់ប្រាក់កើនឡើង ២៨,៨% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២១ ក្នុងនោះ**ចំណាយចរន្ត**អនុវត្តបានចំនួន ១ ១៥៩ ២៤៦ លានរៀល ស្មើនឹង ៣៨,៦% នៃច្បាប់ហិរញ្ញវត្ថុ គឺមានសម្លុះលឿនជាង ១,៤ ពិន្ទុភាគរយ ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២១ ដែលអនុវត្តបាន ៣៧,២% នៃច្បាប់ហិរញ្ញវត្ថុ, បើគិតចំណាយជាសាច់ប្រាក់កើនឡើង ៣១,៨% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២១ (បន្ទុកបុគ្គលិកអនុវត្តបានចំនួន ៣៥៧ ៧៨១ លានរៀល ស្មើនឹង ៤៥,៩% នៃច្បាប់ហិរញ្ញវត្ថុ បើគិតចំណាយជាសាច់ប្រាក់កើនឡើង ១៤,៣% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២១) និង**ចំណាយមូលធន** អនុវត្តបានចំនួន ៣៤ ៤៧២ លានរៀល ស្មើនឹង ៨,៨% នៃច្បាប់ហិរញ្ញវត្ថុ គឺមានសម្លុះយឺតជាង ១៣,៤ ពិន្ទុភាគរយ ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២១ ដែលអនុវត្តបាន ២២,២% នៃច្បាប់ហិរញ្ញវត្ថុ, បើគិតចំណាយជាសាច់ប្រាក់ថយចុះ ២៧,៣% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២១។ **តាមការព្យាករណ៍រហូតដល់ដំណាច់ឆ្នាំ ចំណាយថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ នឹងអាចខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុប្រមាណ ១០,៥% ដោយសារចំណូលពន្ធដារ ថ្នាក់ក្រោមជាតិគ្រោងអនុវត្តខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុប្រមាណ ២០,៩%។**

តារាងទី ៦៖ តារាងចំណាយថវិការដ្ឋបាលថ្នាក់ក្រោមជាតិ					
ប្រតិបត្តិការ	ឆ្នាំ ២០២២				
	ច្បាប់	អនុវត្តធមាសទី ១		ប៉ាន់ស្មានប្រចាំឆ្នាំ	
	ហិរញ្ញវត្ថុ	ទឹកប្រាក់	%ច្បាប់	ទឹកប្រាក់	%ច្បាប់
សរុបចំណាយថវិកាថ្នាក់ក្រោមជាតិ	៣ ៣៩៤ ៨១៤	១ ១៩៣ ៧១៨	៣៥,២%	៣ ៧៥០ ៩៩៦	១១០,៥%
សរុបចំណាយចរន្ត	៣ ០០១ ៧៨៦	១ ១៥៩ ២៤៦	៣៨,៦%	៣ ៣៥៧ ៩៦៨	១១១,៩%
-បន្ទុកបុគ្គលិក	៧៧៩ ៨០១	៣៥៧ ៧៨១	៤៥,៩%	៧៧៩ ៨០១	១០០,០%
-មិនមែនបន្ទុកបុគ្គលិក	២ ២២១ ៩៨៥	៨០១ ៤៦៥	៣៦,១%	២ ៥៧៨ ១៦៨	១១៦,០%
សរុបចំណាយមូលធន	៣៩៣ ០២៨	៣៤ ៤៧២	៨,៨%	៣៩៣ ០២៨	១០០,០%
ក-ចំណាយថវិការាជធានី ខេត្ត	២ ១១៣ ៨៣៣	៦៦៥ ៩៥៦	៣១,៥%	២ ៤៧០ ០១៥	១១៦,៩%
សរុបចំណាយចរន្ត	១ ៧២០ ៨០៥	៦៣១ ៤៨៤	៣៦,៧%	២ ០៧៦ ៩៨៧	១២០,៧%
-បន្ទុកបុគ្គលិក	១៩៨ ០០៧	៤៣ ២៩៤	២១,៩%	១៩៨ ០០៧	១០០,០%
-មិនមែនបន្ទុកបុគ្គលិក	១ ៥២២ ៧៩៨	៥៨៨ ១៩០	៣៨,៦%	១ ៨៧៨ ៩៨០	១២៣,៤%
សរុបចំណាយមូលធន	៣៩៣ ០២៨	៣៤ ៤៧២	៨,៨%	៣៩៣ ០២៨	១០០,០%
ខ-ចំណាយថវិការុក្ខ ស្រុក	៤៣៣ ៦២៤	១៨៩ ៣៤៧	៤៣,៧%	៤៣៣ ៦២៤	១០០,០%
សរុបចំណាយចរន្ត	៤៣៣ ៦២៤	១៨៩ ៣៤៧	៤៣,៧%	៤៣៣ ៦២៤	១០០,០%
-បន្ទុកបុគ្គលិក	២៦២ ៨២២	១៧០ ០៨០	៦៤,៧%	២៦២ ៨២២	១០០,០%
-មិនមែនបន្ទុកបុគ្គលិក	១៧០ ៨០២	១៩ ២៦៧	១១,៣%	១៧០ ៨០២	១០០,០%
សរុបចំណាយមូលធន					
គ-ចំណាយថវិការាយុំ សង្កាត់	៨៤៧ ៣៥៧	៣៣៨ ៤១៥	៣៩,៩%	៨៤៧ ៣៥៧	១០០,០%
សរុបចំណាយចរន្ត	៨៤៧ ៣៥៧	៣៣៨ ៤១៥	៣៩,៩%	៨៤៧ ៣៥៧	១០០,០%
-បន្ទុកបុគ្គលិក	៣១៨ ៩៧២	១៤៤ ៤០៧	៤៥,៣%	៣១៨ ៩៧២	១០០,០%
-មិនមែនបន្ទុកបុគ្គលិក	៥២៨ ៣៨៥	១៩៤ ០០៨	៣៦,៧%	៥២៨ ៣៨៥	១០០,០%

គ- ស្ថានភាពចំណាយអន្តរាគមន៍ប្រយុទ្ធនឹងជំងឺកូវីដ-១៩

ទន្ទឹមគ្នានឹងកិច្ចអន្តរាគមន៍ក្នុងការផ្តល់វ៉ាក់សាំងបង្ការនឹងជំងឺកូវីដ-១៩ ជូនដល់ប្រជាពលរដ្ឋកម្ពុជាគ្រប់រូប ក្នុងការពង្រឹងភាពស៊ាំសហគមន៍ ដែលផ្តល់លទ្ធភាពដល់ប្រជាពលរដ្ឋកម្ពុជា អាចសម្របខ្លួនទៅនឹងគន្លងប្រក្រតីភាពថ្មី ក្នុងការប្រកបមុខរបរ និងការរស់នៅប្រចាំថ្ងៃ, រាជរដ្ឋាភិបាលក៏នៅតែបានអនុវត្តចំណាយអន្តរាគមន៍លើកម្មវិធីសំខាន់ៗ ដូចដែលបានដាក់នៅក្នុងច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០២២ រួមមាន ៖

- កម្មវិធីទប់ស្កាត់ និងព្យាបាលជំងឺកូវីដ-១៩៖ ត្រូវបានគ្រោងបឋមប្រមាណ ៣០០ លានដុល្លារអាមេរិក ប៉ុន្តែមកត្រឹមដំណាច់ខែ មិថុនា ឆ្នាំ ២០២២ បានចំណាយអស់ប្រមាណ ២៣ លានដុល្លារអាមេរិក

ហើយរហូតដល់ដំណាច់ឆ្នាំ ២០២២ ត្រូវបានប៉ាន់ស្មានថានឹងមានតម្រូវការថវិកាត្រឹមប្រមាណ ១០០ លានដុល្លារអាម៉េរិក ដោយសារការកើតមានកាលជាលនៃជំងឺកូវីដ-១៩ បាននិងកំពុងមានការធ្លាក់ស្បើយច្រើន;

- កម្មវិធីបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងឧបត្ថម្ភកម្មករនិយោជិតឲ្យការងារ ត្រូវបានគ្រោងប្រមាណ ៥៩ លានដុល្លារអាម៉េរិក ហើយត្រូវបានប៉ាន់ស្មានថា រហូតដល់ដំណាច់ឆ្នាំ ២០២២ នឹងចំណាយស្មើនឹងឥណទានដែលបានគ្រោងនេះ;
- កម្មវិធីអន្តរាគមន៍ដើម្បីរក្សាលំនឹងជីវភាពប្រជាជនក្រីក្រ៖ ត្រូវបានគ្រោងប្រមាណ ២៨០ លានដុល្លារអាម៉េរិក សម្រាប់រយៈពេល ៩ ខែ ក៏ប៉ុន្តែរាជរដ្ឋាភិបាលបានសម្រេចអនុវត្តបន្ថែម ៣ ខែ ដល់ដំណាច់ឆ្នាំ ២០២២ ដូចនេះត្រូវបន្ថែមចំណាយ ៩៣ លានដុល្លារអាម៉េរិក ថែមទៀត។ ចំណាយសរុបនឹងកើនរហូតដល់ ៣៧៣ លានដុល្លារអាម៉េរិក;
- កម្មវិធីសាច់ប្រាក់ពលកម្ម៖ ត្រូវបានផ្ទេរថវិកាចំនួន ១០០ លានដុល្លារអាម៉េរិក តាមការគ្រោងទុកដើម្បីអនុវត្តសកម្មភាពការងារហេដ្ឋារចនាសម្ព័ន្ធរូបវន្តដោយដៃនៅតាមមូលដ្ឋាន ជាពិសេសហេដ្ឋារចនាសម្ព័ន្ធស្រោចស្រព ដើម្បីជំរុញផលិតកម្មស្បៀង និងសន្តិសុខស្បៀង ក្នុងបរិការណ៍នៃការឡើងថ្លៃស្បៀង និងម្ហូបអាហារ;
- កម្មវិធីហិរញ្ញប្បទានគាំទ្រកម្មវិធីស្តារ និងជំរុញកំណើនសេដ្ឋកិច្ច ក្នុងគន្លងប្រក្រតីភាពថ្មី ត្រូវបានគ្រោងចំនួន ២៥០ លានដុល្លារអាម៉េរិក ដែលនឹងត្រូវផ្តល់ហិរញ្ញប្បទាន ដោយការបោះផ្សាយមូលបត្ររដ្ឋជាលើកដំបូង ហើយកំពុងដំណើរការនីតិវិធី។

ជារួម, តាមការគ្រោងទុកពីដើមឆ្នាំ ២០២២ ចំណាយអន្តរាគមន៍ប្រយុទ្ធនឹងជំងឺកូវីដ-១៩ ត្រូវបានគ្រោងចំនួន ៩៨៩ លានដុល្លារអាម៉េរិក ក៏ប៉ុន្តែ ដោយសារស្ថានភាពវិបត្តិនៃជំងឺកូវីដ-១៩ បាននិងកំពុងមានភាពធ្លាក់ស្បើយច្រើន រាជរដ្ឋាភិបាលអាចសន្សំថវិកាអន្តរាគមន៍ប្រយុទ្ធនឹងជំងឺកូវីដ-១៩ បានមួយចំនួន ដែលអាចឆ្លើយតបបានទៅនឹងតម្រូវការថ្មីផ្សេងទៀតចំពោះមុខ រួមមាន៖ ការបន្ថែមថវិកាប្រមាណ ៩៣ លានដុល្លារអាម៉េរិក សម្រាប់បន្តអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះ សម្រាប់រយៈពេល ៣ ខែបន្ថែម រហូតដល់ដំណាច់ឆ្នាំ ២០២២ និងតម្រូវការចំណាយមុនប្រមាណ ៥០ លានដុល្លារអាម៉េរិក នៅក្នុងឆ្នាំ ២០២២ សម្រាប់ការត្រៀមរៀបចំការប្រកួតកីឬាអាស៊ីអាគ្នេយ៍ (SEAGAMES) ឆ្នាំ ២០២៣។

៣.២.៤-ហិរញ្ញប្បទានសហប្រតិបត្តិការ

ក-ការជកសាច់ប្រាក់

ចុងឆ្នាំ២ ២០២២ មានឥណទានវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេសចំនួន ៥ ៨១៣ ៤៨៤ លានរៀល។ ជាក់ស្តែង ការជកសាច់ប្រាក់យកមកប្រើប្រាស់ក្នុងគម្រោង/កម្មវិធីអភិវឌ្ឍន៍ នៅក្នុងឆមាសទី ១ ឆ្នាំ ២០២២ ក្នុងក្របខ័ណ្ឌនៃកិច្ចព្រមព្រៀងឥណទានសម្ព្ធទាន និងកិច្ចព្រមព្រៀងហិរញ្ញប្បទានឥតសំណង តាមបរិបថរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រេចបានសរុបប្រមាណ ៥២៤,២៣ លានដុល្លារអាម៉េរិក ស្មើនឹងចំនួនប្រមាណ ២ ១៣០,៣៩ ប៊ីលានរៀល គឺស្មើនឹងប្រមាណ ៣៦,៦៥% នៃចុងឆ្នាំ ២០២២ ក្នុងនោះ៖ ឥណទានសម្ព្ធទានសម្រេចបានចំនួន ៤៧៣,៩៤ លានដុល្លារអាម៉េរិក ស្មើនឹងប្រមាណ ១ ៩២៦,២៧ ប៊ីលានរៀល គឺស្មើនឹងប្រមាណ ៣៨,២៤% នៃឥណទានប្រចាំឆ្នាំ និងហិរញ្ញប្បទានឥតសំណង សម្រេចបានចំនួន ៥០,២៩ លានដុល្លារអាម៉េរិក ស្មើនឹងចំនួនប្រមាណ ២០៤,១១ ប៊ីលានរៀល គឺស្មើនឹងប្រមាណ ២៦,៣០% នៃឥណទានប្រចាំឆ្នាំ។ ទឹកប្រាក់នេះនៅមិនទាន់បញ្ចូលនៅឡើយនូវហិរញ្ញប្បទានឥតសំណង

មួយចំនួនទៀត ដែលត្រូវបានផ្តល់ទៅដល់គោលដៅអនុវត្តផ្ទាល់ដោយដៃគូអភិវឌ្ឍន៍តែម្តង ដោយមិនឆ្លងតាមបរិបថក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយរួមទាំងគម្រោងវិនិយោគផ្ទាល់ក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម និងគម្រោងកសាងសមត្ថភាពផងដែរ។

ខ-ការចុះកិច្ចព្រមព្រៀងថ្មី

ក្នុងឆមាសទី ១ ឆ្នាំ ២០២២ រាជរដ្ឋាភិបាលបានចុះកិច្ចព្រមព្រៀងហិរញ្ញប្បទានឥតសំណង និងឥណទានសម្បទាន មានទឹកប្រាក់សរុបចំនួនប្រមាណ ៧៦២,៧៦ លានដុល្លារអាម៉េរិក សម្រាប់អនុវត្ត ១៨ គម្រោង/កម្មវិធីអភិវឌ្ឍន៍ ដែលក្នុងនោះមាន៖

- ហិរញ្ញប្បទានឥតសំណងចំនួន ៩ គម្រោង/កម្មវិធី មានទឹកប្រាក់សរុបចំនួនប្រមាណ ១២៧,១៧៨ លានដុល្លារអាម៉េរិក។ ទឹកប្រាក់នេះមិនរាប់បញ្ចូលទឹកប្រាក់ហិរញ្ញប្បទាន ដែលដៃគូអភិវឌ្ឍន៍បានផ្តល់ទៅដល់បណ្តាគោលដៅអនុវត្តដោយផ្ទាល់ដោយមិនឆ្លងកាត់រាជរដ្ឋាភិបាលទេ។
- ឥណទានសម្បទានចំនួន ៩ គម្រោង/កម្មវិធី មានទឹកប្រាក់សរុបចំនួនប្រមាណ ៦៣៥,៥៩ លានដុល្លារអាម៉េរិក ឬប្រមាណ ៤៧៤,៤៨លានអេសដេអែ គឺស្មើនឹងប្រមាណ ២៩,៦៥% នៃច្បាប់ហិរញ្ញវត្ថុ។

គ-បញ្ហាប្រឈម

ទោះបីជាការរីករាលដាលនៃជំងឺកូវីដ-១៩ បានស្រាកស្រាន្តនៅក្នុងពេលប៉ុន្មានសប្តាហ៍ចុងក្រោយនេះ ការរីករាលដាលនៃជំងឺនេះ នៅដើមឆ្នាំ ២០២២ បានធ្វើឱ្យប៉ះពាល់ដល់ការអនុវត្តគម្រោង ជាពិសេស ការ-បណ្តុះបណ្តាលពង្រឹងសមត្ថភាពមន្ត្រីអនុវត្តគម្រោង, ការសិក្សាកសាងគម្រោងថ្មី និងការធ្វើដំណើររបស់ទីប្រឹក្សាអន្តរជាតិដែលត្រូវបម្រើការងារឱ្យគម្រោងអភិវឌ្ឍន៍ក្នុងប្រទេស។

៣.២.៥-ការប៉ាន់ស្មាន និងការវាយតម្លៃលើការអនុវត្តចំណាយឆ្នាំ ២០២២

ជាមួយនឹងការលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រងមន្ត្រីរាជការ **ចំណាយបន្ទុកបុគ្គលិក** ពិសេសបៀវត្សរបស់មន្ត្រីរាជការឆ្នាំ ២០២២ ត្រូវបានក្សាកម្រិតប្រាក់បៀវត្សអប្បបរមា និងប្រាក់បៀវត្សមន្ត្រីរាជការស៊ីវិល និងកម្លាំងប្រដាប់អាវុធ ស្មើនឹងកម្រិតឆ្នាំ ២០២១ ដើម្បីសន្សំថវិកាសម្រាប់ទប់ទល់ការរាតត្បាតនៃជំងឺកូវីដ-១៩ ដែលបានបង្កនូវផលប៉ះពាល់ដល់សុខភាព សេដ្ឋកិច្ច សង្គម និង ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ពិសេសកម្មករនិយោជិក ក្នុងវិស័យកាត់ដេរ និងវាយនកណ្ឌ កម្មករក្រៅប្រព័ន្ធ ព្រមទាំង ប្រជាជនក្រីក្រ និងជនងាយរងគ្រោះ។ តាមរយៈវិធានការខាងលើ នៅក្នុងឆ្នាំ ២០២២, **បៀវត្សអប្បបរមាមន្ត្រីរាជការស៊ីវិល** ត្រូវបានក្សាស្មើនឹងប្រមាណ **១ ១៧២ ៥០០** រៀល, **បៀវត្សអប្បបរមាគ្រូបង្រៀន និងគ្រូពេទ្យ** ត្រូវបានក្សាស្មើនឹងប្រមាណ **១ ២៧២ ៥០០** រៀល, **បៀវត្សអប្បបរមានគរបាលជាតិ** (ពលបាលត្រី) ត្រូវបានក្សាស្មើនឹងប្រមាណ **១ ២៥៦ ៩៧៧** រៀល (គិតបញ្ចូលរបបអង្ករ), **បៀវត្សអប្បបរមាយោធិន** (ពលទោ) ក្សាស្មើនឹងប្រមាណ **១ ១២៣ ៥០០** រៀល (មិនគិតបញ្ចូលរបបអង្ករ) ហើយបើគិតបញ្ចូលរបបអង្ករត្រូវជាប្រមាណ **១ ១៨១ ៩៧៧** រៀល។ ចំពោះប្រាក់បំណាច់របស់មន្ត្រីជាប់កិច្ចសន្យា ក៏ត្រូវបានក្សាស្មើនឹងចំនួន ៦៧ ម៉ឺនរៀលផងដែរ។ ទន្ទឹមនេះ មន្ត្រីរាជការទូទៅ ក៏ដូចជានិវត្តជនជាអតីតមន្ត្រីរាជការ និងអតីតយុទ្ធជន ក៏ត្រូវបានផ្តល់ប្រាក់ឧបត្ថម្ភ **៥ ម៉ឺនរៀល** សម្រាប់ការចូលឆ្នាំប្រពៃណីខ្មែរ និងបុណ្យភ្ជុំបិណ្ឌ។ ជាមួយគ្នានេះដែរ រាជរដ្ឋាភិបាលក៏បានផ្តល់ថវិកាសម្រាប់ការអនុវត្តមូលនិធិថែទាំសុខភាពមន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន ដើម្បីរ៉ាប់រងលើការទ្រទ្រង់ថែទាំសុខភាពមន្ត្រីសាធារណៈ បន្ថែមពីលើប្រាក់ឧបត្ថម្ភគោលនយោបាយតាំពីរសង្គមចំនួនពីរ គឺប្រាក់ឧបត្ថម្ភមាតុភាពដល់មន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទជាស្ត្រី និងប្រាក់

ឧបត្ថម្ភបុណ្យសពមន្ត្រីរាជការដែលទទួលមរណភាពក្នុងពេលបំពេញបេសកកម្ម ឬគ្រោះថ្នាក់ការងារ ដើម្បីរៀបចំពិធីបុណ្យសពតាមប្រពៃណី ដែលត្រូវបានដាក់ឱ្យអនុវត្តរួចមកហើយ; និងសម្រាប់កញ្ចប់ថវិកាទ្រទ្រង់របបសន្តិសុខសង្គមផ្នែកហានិភ័យការងារសម្រាប់មន្ត្រីសាធារណៈ។

នៅក្នុងឆ្នាំ ២០២២ នេះដែរ រាជរដ្ឋាភិបាលបានសម្រេច និងកំពុងរៀបចំនីតិវិធីដើម្បីដំឡើងរបបសោធនអប្បបរមារបស់និវត្តជនជាអតីតមន្ត្រីរាជការស៊ីវិល និងអតីតយុទ្ធជន ព្រមទាំងដើម្បីកាត់បន្ថយគម្លាតរវាងអ្នកចូលនិវត្តន៍ចាស់ និងអ្នកចូលនិវត្តន៍ថ្មី ដែលត្រូវចំណាយថវិកាប្រមាណ ៧០ ប៊ីលានរៀល សម្រាប់អនុវត្ត ១២ ខែ (ខែ មករា ដល់ខែ ធ្នូ)។

ចំណែកឯ **ចំណាយមិនមែនបន្ទុកបុគ្គលិក** របស់ក្រសួង-ស្ថាប័ន ក្នុងឆមាសទី ២ ខាងមុខ អាចនឹងមានសម្ទុះលឿនជាងនៅក្នុងឆមាសទី ១ ហើយនឹងត្រូវបានតម្រង់ការអនុវត្តចំណាយឱ្យចំទិសដៅ ព្រោះមានការដាក់ចេញវិធានការចាំបាច់មួយចំនួនដើម្បីជំរុញការអនុវត្តចំណាយនៅឆមាសទី ២ នេះផង និងពង្រឹងប្រសិទ្ធភាពប្រតិបត្តិចំណាយផងដែរ។ លើសពីនេះ កញ្ចប់ឥណទានថវិកាមិនទាន់បែងចែករបស់រាជរដ្ឋាភិបាល ដែលមានចំនួន ១ ៦១៨ ២៦៤ លានរៀល គិតត្រឹមឆមាសទី ១ ឆ្នាំ ២០២២ បានផ្ទេរចេញទៅក្រសួង-ស្ថាប័ន ដើម្បីបំពេញសេចក្តីត្រូវការចាំបាច់នានា ក៏ដូចជាការអនុវត្តអាទិភាពគោលនយោបាយបន្ទាន់របស់រដ្ឋាភិបាល ចំនួន ១៣៥ ១៨៧ លានរៀល រួចហើយ។ ឥណទាននៅសល់ក៏មានមុខសញ្ញាចំណាយហើយដែរ ពិសេសគឺការត្រៀមសម្រាប់ចំណាយចាំបាច់មួយចំនួនផ្សេងទៀតរបស់រាជរដ្ឋាភិបាល នាពេលខាងមុខនេះ។

ជារួម ផ្អែកលើលទ្ធផលអនុវត្តក្នុងឆមាសទី ១ និងនិន្នាការចំណាយឆមាសទី ២ អាចសន្និដ្ឋានបានថា **ការអនុវត្តចំណាយឆ្នាំ ២០២២ នឹងទាបជាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២២ បន្តិចបន្តួចក្នុងរង្វង់ប្រមាណ ០,២%**, ដោយសាររាជរដ្ឋាភិបាល បាននិងកំពុងកាត់បន្ថយចំណាយលើចំណាយអន្តរាគមន៍ប្រយុទ្ធនឹងជំងឺកូវីដ-១៩ ព្រោះស្ថានភាពវិបត្តិនៃជំងឺកូវីដ-១៩ បាននិងកំពុងមានភាពធូរស្បើយច្រើន។

ដូចនេះ ផ្អែកលើលទ្ធផលនៃការអនុវត្តចំណាយតាមផែនការដែលបានគ្រោងទុក និងប្រកបដោយប្រសិទ្ធភាពខ្ពស់នេះ រាជរដ្ឋាភិបាលនឹងសម្រេចបានគោលដៅ និងសមិទ្ធកម្មដែលកើតចេញពីការអនុវត្តគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាល រួមមាន៖ ការបន្តប្រយុទ្ធការពារអាយុជីវិតប្រជាជន រក្សាលំនឹងសង្គម-សេដ្ឋកិច្ច និងជីវភាពរស់នៅរបស់ប្រជាជន ព្រមទាំងការស្តារ និងជំរុញកំណើនសេដ្ឋកិច្ចឡើងវិញ ទន្ទឹមនឹងការបន្ត និងរក្សាភាពប្រតិបត្តិការរបស់រដ្ឋក្នុងបរិការណ៍កូវីដ-១៩, ការអភិវឌ្ឍធនធានមនុស្សកាន់តែមានគុណភាពខ្ពស់, ការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត, ការលើកកម្ពស់គុណភាពសេវាសុខាភិបាលឱ្យកាន់តែល្អប្រសើរ, ការអភិវឌ្ឍ និងបង្កើនតម្លៃបន្ថែមនៃវិស័យកសិកម្ម, ការកែលម្អប្រព័ន្ធអប់រំឱ្យកាន់តែមានគុណភាពខ្ពស់, ការពង្រឹងស្ថាប័នជាតិ និងថ្នាក់ក្រោមជាតិ ជាពិសេសការជំរុញអនុវត្តកម្មវិធីថ្មីៗនៃគោលនយោបាយក្នុងវិស័យសង្គមកិច្ចពាក់ព័ន្ធនឹងការគាំពារសង្គម ដោយឈរលើគោលការណ៍ប្រសិទ្ធភាព ទាំងក្នុងកម្រិតវិភាជន៍ និងទាំងក្នុងកម្រិតប្រតិបត្តិការ និងបច្ចេកទេស។

ជាមួយនឹងការវាយតម្លៃអំពីទិដ្ឋភាពនៃការអនុវត្តចំណាយថវិកាកន្លងមក និងរហូតដល់ដំណាច់ឆ្នាំ ផ្នែកចំណាយអាចជួបប្រទះ**បញ្ហាប្រឈម**មួយចំនួន ដូចខាងក្រោម៖

- ការធានាប្រសិទ្ធភាពផ្នែកប្រតិបត្តិការចំណាយ (ចាយឱ្យចំមុខសញ្ញា និងចាយតែចំណាយចាំបាច់, មិនចាយលើមុខសញ្ញាមិនចាំបាច់ ឬមិនទាន់ចាំបាច់ និងការធានា "តម្លៃនៃលុយ") នៅជាបញ្ហាប្រឈមនៅឡើយ នៅក្នុងការអនុវត្តចំណាយរបស់ក្រសួង-ស្ថាប័នមួយចំនួន,

• សមត្ថភាពរបស់មន្ត្រីទទួលបន្ទុកហិរញ្ញវត្ថុ រដ្ឋទេយ្យករបុរេប្រទាន និងក្រុមលទ្ធកម្ម នៅមិនទាន់យល់ច្បាស់អំពីនីតិវិធីហិរញ្ញវត្ថុដែលមានជាធរមាននៅឡើយ។ ប្រការនេះ នាំឱ្យការអនុវត្តចំណាយមិនមែនបន្ទុកបុគ្គលិករបស់ក្រសួង-ស្ថាប័នខ្លះ នៅមានសម្ទុះយឺតបើធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២១,

• ការអនុវត្តចំណាយមិនមែនបន្ទុកបុគ្គលិករបស់ក្រសួង ស្ថាប័នខ្លះ នៅក្នុងឆមាសទី ១ នៃឆ្នាំ ២០២២ នេះ មានសម្ទុះយឺតបើធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២១ គឺដោយសារការផ្តល់ធានាចំណាយនៃចំណាយចរន្តត្រូវបានចែកជាពីរដំហាន លើមុខសញ្ញាចំណាយកិច្ចលទ្ធកម្មដែលមានទំហំឥណទានធំជាង ១ ០០០ លានរៀល។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានផ្តល់ធានាចំណាយត្រឹម ៥០% សិន នៅឆមាសទី ១ ដើម្បីត្រៀមទប់ទល់នឹងការធ្លាក់ចុះចំណូលជាយថាហេតុ ពីការបន្តទទួលរងផលប៉ះពាល់ពីជំងឺកូវីដ-១៩ និងផលប៉ះពាល់ពីសង្គ្រាមនៅអ៊ុយក្រែន,

• ការស្នើសុំធានាចំណាយកិច្ចលទ្ធកម្ម ដោយគ្មានផែនការលទ្ធកម្ម ដោយសារមិនបានដាក់បញ្ចូលមុខសញ្ញាចំណាយដែលត្រូវធ្វើលទ្ធកម្មទៅក្នុងផែនការលទ្ធកម្ម ក្រោយមានការកែសម្រួលតារាងឧបសម្ព័ន្ធរដ្ឋទេយ្យបុរេប្រទាន,

• ទន្ទឹមបញ្ហាប្រឈមកើតមានឡើងលើការអនុវត្តផ្នែកចំណាយចរន្ត, ក្រសួង-ស្ថាប័នមួយចំនួនដែលទទួលបាននូវឥណទានចំណាយមូលធនដោយហិរញ្ញប្បទានក្នុងស្រុក ក៏មានការយឺតយ៉ាវនៅក្នុងការអនុវត្តចំណាយនេះផងដែរ គឺដោយសារ, ម្យ៉ាង, ការកើនឡើងនៃតម្លៃប្រេង និងតម្លៃសម្ភារៈ ក្រសួង ស្ថាប័នមួយចំនួនបានស្នើសុំដកសំណើសុំធានាចំណាយទៅវិញ ដើម្បីកែសម្រួលទឹកប្រាក់គម្រោងឱ្យស្របតាមតម្លៃប្រេង និងសម្ភារជាក់ស្តែង និង ម្យ៉ាងទៀត ក្រសួង-ស្ថាប័នខ្លះបានស្នើសុំកែប្រែទឹកប្រាក់គម្រោង និងយថាប្រភេទបន្ទាប់ពីទទួលបានគោលការណ៍ធានាចំណាយរួចហើយ និងក្រសួង-ស្ថាប័នខ្លះទៀត ស្នើសុំធានាចំណាយយឺតយ៉ាវ ទោះបីមានគោលការណ៍រួចហើយក៏ដោយ។ ទន្ទឹមនេះ, ភ្លៀងធ្លាក់ច្រើននាដើមរដូវវស្សា ធ្វើឱ្យប៉ះពាល់ដល់វឌ្ឍនភាពជារូបវន្តនៃការងារសាងសង់ ជួសជុល ហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ដែលនាំឱ្យប៉ះពាល់ដល់ការទូទាត់ថវិកា ជាពិសេសក្រសួងធំៗ ដូចជា ក្រសួងសាធារណការនិងដឹកជញ្ជូន, ក្រសួងអភិវឌ្ឍន៍ជនបទ, ក្រសួងធនធានទឹកនិងឧតុនិយម និងក្រសួងអប់រំ យុវជន និងកីឬ ។ល។ ដូចគ្នានឹងផ្នែកចំណាយចរន្តដែរ, ការផ្តល់ធានាចំណាយសម្រាប់គម្រោងវិនិយោគត្រូវបានចែកជាពីរដំហាន ដោយផ្តល់ធានាចំណាយត្រឹម ៥០% សិន នៅឆមាសទី ១ សម្រាប់បញ្ជីគម្រោងអាទិភាពទី ១ របស់ក្រសួងសាធារណការនិងដឹកជញ្ជូន, ក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងធនធានទឹកនិងឧតុនិយម។

៣.២.៦-តុល្យភាពចំណូល-ចំណាយឆមាសទី ១ និង ការវាយតម្លៃការអនុវត្តថវិកាឆ្នាំ ២០២២

ជារួម ចំណូលថវិកាថ្នាក់ជាតិឆមាសទី ១ ឆ្នាំ ២០២២ អនុវត្តបាន ៥៧,០% នៃច្បាប់ហិរញ្ញវត្ថុ គឺមានសម្ទុះលឿនជាង ១,២ ពិន្ទុភាគរយ ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២១ ទោះបីជាការផ្ទុះឡើងនូវសង្គ្រាមរវាងរុស្សី និងអ៊ុយក្រែន ដែលបានបង្កផលប៉ះពាល់មកលើទំនុកចិត្តវិនិយោគ និងជាពិសេសការកើនឡើងថ្លៃប្រេង និងទំនិញសំខាន់ៗក៏ដោយ។ ចំណែកឯផ្នែកចំណាយវិញ, ការអនុវត្តសម្រេចបានល្អប្រសើរជាងឆ្នាំ ២០២១ ពោលគឺសម្រេចបាន ៤២,៥% (គិតទាំងបុរេប្រទាន) នៃច្បាប់ហិរញ្ញវត្ថុ។

ដូចនេះ ផ្អែកលើលទ្ធផលនៃការអនុវត្តចំណូល និងចំណាយក្នុងឆមាសទី ១ ឆ្នាំ ២០២២ នេះ, បើគិតតាមអាណត្តិបើកប្រាក់ ថវិកាថ្នាក់ជាតិមានអតិរេកជាបណ្តោះអាសន្នរហូតដល់ប្រមាណ ២ ៧១៨ ១៥៥ លានរៀល។ ពិតប្រាកដណាស់ នៅពេលគ្រប់ក្រសួង-ស្ថាប័នបង្កើនល្បឿននៃការអនុវត្តចំណាយនៅក្នុងឆមាសទី ២ រួមទាំងការផ្តល់ធានាចំណាយ ៥០% ជំហានទី ២ លើមុខចំណាយមានឥណទានធំជាង ១ ០០០ លានរៀល, នោះតាមការប៉ាន់ស្មានដល់ដំណាច់ឆ្នាំ នឹងមានវិនិភាពថវិកាក្នុងរង្វង់ -២៩៥ ៥៥៣ លានរៀល សមមូលស្មើនឹងប្រមាណ **៧៣ លានដុល្លារអាម៉េរិក**។ ផ្អែកតាមការប៉ាន់ស្មាននេះ, វិនិភាពថវិការដ្ឋសរុបនឹងមានទំហំស្មើនឹង -៦,៦០% នៃ ផសស គឺទាបជាងពីកម្រិតនៃវិនិភាព ដែលបានគ្រោងក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២២ ដែលស្មើនឹង -៧,៥៨% នៃ ផសស **និងបានគ្រោងប្រើប្រាស់ប្រាក់សន្សំរបស់រាជរដ្ឋាភិបាល ដើម្បីបំពេញតុល្យភាពថវិការហូតដល់ប្រមាណ -២ ០៣២ ៥០០ លានរៀល សមមូលស្មើនឹងប្រមាណ ៥០០ លានដុល្លារអាម៉េរិក**។ ក៏ប៉ុន្តែ **ក្នុងករណីការបោះផ្សាយលក់មូលបត្ររដ្ឋចំនួន ៣០០ លានដុល្លារអាម៉េរិក មិនអាចធ្វើទាន់ពេលក្នុងឆ្នាំ ២០២២ នេះ, វិនិភាពថវិកាសរុប នឹងកើនឡើងដល់ចំនួន-៧,៦២% ផសស ហើយប្រាក់សន្សំរបស់រាជរដ្ឋាភិបាល នឹងត្រូវបានប្រើប្រាស់សរុបអាចដល់ ៣៧៣ លានដុល្លារអាម៉េរិក**។

តារាងទី ៧: តារាងតុល្យភាពថវិការដ្ឋ					
សូចនាករ	**២០២០**	**២០២១**		**២០២២**	
	អនុវត្ត	**ច្បាប់**	**អនុវត្ត**	**ច្បាប់**	**ប៉ាន់ស្មាន**
ផសស (លានរៀល)	១០៩ ០៦១ ៩០៧	១១០ ៥០៥ ៩១៦		១២០ ៣១២ ៤៧៧ (**)	
ចំណូលក្នុងប្រទេស (%ផសស)	២១,៨១%	១៩,៤១%	២០,៦៥%	២១,២៧%	២២,១៩%
- ចំណូលចរន្ត (%ផសស)	២១,៦៤%	*១៩,២១%*	*២០,៦០%*	២០,១៩%	២១,១៣%
ចំណាយសរុបថវិការដ្ឋ (%ផសស)	២៨,៨០%	២៨,៩៧%	៣១,០៣%	២៨,៨៥%	២៨,៧៩%
- ចំណាយចរន្ត (%ផសស)	១៧,២៥%	*១៦,៩៧%*	*១៩,៥៣%*	១៧,៣៣%	១៧,៣៦%
អតិរេកចរន្ត (%ផសស)	៤,៣៩%	២,២៤%	១,០៧%	២,៨៦%	៣,៧៧%
វិនិភាពសរុប (%ផសស)	-៧,០០%	-៩,៥៦%	-១០,៣៧%	-៧,៥៨%	-៦,៦០%

*<u>សេចក្តីបញ្ជាក់</u>: (* *) ផសស គិតជាទឹកប្រាក់តាមថ្លៃបច្ចុប្បន្នតាមការប៉ាន់ស្មាននៅពាក់កណ្តាលឆ្នាំ ២០២២*

អតិរេកថវិកាជាបណ្តោះអាសន្ននៅក្នុងឆមាសទី ១ ឆ្នាំ ២០២២ មានចំនួនប្រមាណ ២ ៧១៨ ១៥៥ លានរៀល បានជួយឱ្យការបើកផ្តល់សាច់ប្រាក់មានភាពរលូន ដែលជាសូចនាករយ៉ាងសំខាន់ សម្រាប់ការវាយតម្លៃអំពីភាពជឿជាក់នៃថវិកា ក្នុងក្របខ័ណ្ឌនៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដោយសារការពង្រឹងប្រសិទ្ធភាពប្រតិបត្តិការចំណាយ ។

ជាសរុប ផ្អែកតាមការប៉ាន់ស្មាននៃការអនុវត្តថវិកាដល់ដំណាច់ឆ្នាំ វិនិភាពថវិកាឆ្នាំ ២០២២ ដែលបានប៉ាន់ស្មានថាមានចំនួនប្រមាណ -២៩៥ ៥៥៣ លានរៀល គឺចំណុះខ្លាំងទៅនឹងលទ្ធផលនៃការអនុវត្តការប្រមូលចំណូលនៅឆមាសទី ២ ឆ្នាំ ២០២២។ ដូចនេះ ការខកខានក្នុងការសម្រេចបានលទ្ធផលចំណូលតាមការប៉ាន់ស្មានដល់ដំណាច់ឆ្នាំ ក៏ដូចជាការបោះផ្សាយលក់មូលបត្ររដ្ឋ មិនទាន់ពេលក្នុងឆ្នាំ ២០២២ នេះ

នឹងធ្វើឱ្យប៉ះពាល់ជាអវិជ្ជមានថែមទៀតដល់តុល្យភាពដែលបានព្យាករណ៍។ ផ្ទុយទៅវិញ បើការប្រមូលចំណូលសម្រេចបានលទ្ធផលកាន់តែល្អវិញ នោះតុល្យភាពថវិកានៅក្នុងឆ្នាំក៏អាចនឹងប្រែប្រួលជាវិជ្ជមានវិញខ្លះផងដែរ។

៤-វិធានការជះស្រាយសម្រាប់ការអនុវត្តថវិកាឆ្នាំ ២០២២

ដើម្បីសម្រេចបាននូវកំណើនសេដ្ឋកិច្ចប្រចាំឆ្នាំដូចដែលបានគ្រោងទុក និងការអនុវត្តថវិកាទាំងផ្នែកចំណូល និងចំណាយទទួលបានលទ្ធផលល្អប្រសើរ វិធានការចាំបាច់ និងមុតស្រួចមួយចំនួនដែលត្រូវដាក់ចេញ និងអនុវត្តឱ្យបានទាន់ពេលវេលា និងប្រកបដោយធនធានខ្ពស់ រួមមាន៖

៤.១-វិធានការផ្នែកម៉ាក្រូសេដ្ឋកិច្ច

ក្នុងបរិបទនេះ ដើម្បីឆ្លើយតបនឹងនិន្នាការថ្មីៗ ក៏ដូចជាគ្រប់គ្រងហានិភ័យដែលអាចកើតមាន, រាជរដ្ឋាភិបាលបាន និងកំពុងដាក់ឱ្យអនុវត្តនូវវិធានការអន្តរាគមន៍សមស្រប និងទាន់ពេលវេលា តាមរយៈការដាក់ចេញដោយប្រទាក់ក្រឡានូវគោលនយោបាយហិរញ្ញវត្ថុសាធារណៈ, គោលនយោបាយរូបិយវត្ថុ និងគោលនយោបាយជារចនាសម្ព័ន្ធ ដើម្បីសម្រេចឱ្យបាននូវការការពារ និងជំរុញកំណើនសេដ្ឋកិច្ច។ ចំពោះមុខ, រាជរដ្ឋាភិបាលបានដាក់ចេញ និងបន្តជំរុញការអនុវត្ត "**ក្របខ័ណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា ក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី សម្រាប់ឆ្នាំ ២០២១-២០២៣**" ក្នុងគោលបំណងស្តារ និងពង្រឹងសក្តានុពលនៃចន្លប់កំណើនសេដ្ឋកិច្ចឱ្យរស់រវើក និងត្រឡប់ទៅរកកំណើនសក្តានុពល ប្រកបដោយចីរភាព និងបរិយាបន្ន, ចាប់យកឱ្យបាននូវកាលានុវត្តភាពថ្មីៗដែលកំពុងលេចឡើងស្របនឹងនិន្នាការតំបន់ និងសកល និងកសាងភាពធន់នៃសង្គម-សេដ្ឋកិច្ច។ ជាមួយគ្នានេះ ជាទិសដៅយុទ្ធសាស្ត្រ និងគោលនយោបាយ, រាជរដ្ឋាភិបាលកម្ពុជា នឹងបន្តជំរុញការកែទម្រង់ជារចនាសម្ព័ន្ធ និងជាប្រព័ន្ធ ព្រមទាំងពង្រឹងការកសាងភាពធន់នៃសេដ្ឋកិច្ច និងសង្គម ឱ្យកាន់តែរឹងមាំ និងមានភាពឆ្លើយតបខ្ពស់ ដោយផ្តោតលើអាទិភាពចំនួន ៤ រួមមាន៖

- **បន្តពង្រឹងរដ្ឋបាលសាធារណៈ** តាមរយៈការបន្តកែទម្រង់ស្ថាប័នរដ្ឋឱ្យខានតែបាន ដោយផ្តោតលើការពង្រឹងសមត្ថភាព និងប្រសិទ្ធភាពក្នុងការអនុវត្តការងាររបស់ស្ថាប័នរដ្ឋ, ការសម្រិតសម្រាំងមន្ត្រីមានសមត្ថភាពខ្ពស់ និងគុណវុធិល្អ ព្រមទាំងការលើកកម្ពស់ការទទួលខុសត្រូវ និងភាពម្ចាស់ការរបស់ក្រសួង-ស្ថាប័ន ដើម្បីឈានទៅសម្រេចបានរដ្ឋបាលសាធារណៈស្អាតស្អំ ឆ្លាតវៃ និងមានសមត្ថភាពខ្ពស់។
- **បន្តជំរុញការកសាងភាពធន់នៃសេដ្ឋកិច្ច** តាមរយៈការពន្លឿនការធ្វើពិពិធកម្មសេដ្ឋកិច្ច និងការលើកកម្ពស់ភាពប្រកួតប្រជែង ដោយផ្តោតលើការចាប់យកដៃគូពាណិជ្ជកម្មក្នុងក្របខ័ណ្ឌទ្វេភាគី និងពហុភាគី, ការធ្វើឱ្យប្រសើរឡើងនូវបរិយាកាសវិនិយោគ និងកិច្ចសម្រួលពាណិជ្ជកម្ម, ការជំរុញឌីជីថលូបនីយកម្មសង្គម-សេដ្ឋកិច្ច ទាំងវិស័យសាធារណៈ និងវិស័យឯកជន, ជាពិសេស ការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត, ឡូជីស្ទីក, ថាមពល, បៃតង និងឌីជីថល ប្រកបដោយគុណភាពខ្ពស់។
- **ពន្លឿនការកសាងភាពធន់នៃសង្គម** តាមរយៈការបន្តអភិវឌ្ឍប្រព័ន្ធសុខាភិបាល និងប្រព័ន្ធគាំពារសង្គមទាំងគុណភាព និងវិសាលភាព ដើម្បីត្រៀមខ្លួនឆ្លើយតបទៅនឹងបិត្តិ ឬហានិភ័យនានា ដែលអាចកើតឡើងជាយថាហេតុនាពេលអនាគត ព្រមទាំងការបន្តអភិវឌ្ឍធនធានមនុស្ស ដោយផ្តោតលើការពង្រឹងគុណភាពនៃវិស័យអប់រំ និងជំនាញបច្ចេកទេស។

- ជំរុញការកសាងភាពធន់នៃប្រព័ន្ធហិរញ្ញវត្ថុ តាមរយៈការបន្តអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធបច្ចេកវិទ្យាហិរញ្ញវត្ថុ និងសមត្ថភាពរបស់ប្រព័ន្ធហិរញ្ញវត្ថុឱ្យកាន់តែមានពិពិធភាព, រឹងមាំធន់នឹងវិបត្តិ និងប្រកបដោយបរិយាប័ន្ន សំដៅគាំទ្រសកម្មភាពសេដ្ឋកិច្ចទាំងមូល និងដល់ការសម្របខ្លួន និងឆ្លើយតបទៅនឹងការប្រែប្រួលនៃសមាហរណកម្មសេដ្ឋកិច្ច និងហិរញ្ញវត្ថុក្នុងតំបន់ និងសកល និងតាមរយៈការបន្តពង្រឹងប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ដោយផ្តោតលើការធ្វើទំនើបកម្ម និងវិចារណកម្មប្រព័ន្ធគ្រប់គ្រងចំណាយថវិកា និងគ្រប់គ្រងបំណុលសាធារណៈ ឱ្យមានប្រសិទ្ធភាព និងចីរភាព ព្រមទាំងការបន្តពង្រឹងប្រព័ន្ធត្រួតពិនិត្យ និងប្រព័ន្ធឆ្លើយតបនឹងវិបត្តិរបស់ធនាគារ ជាដើម។

៤.២-វិធានការផ្នែកថវិកា

ក្នុងឆ្នាំ ២០២២ នេះ នៅពេលដែលចំណូលប្រចាំឆ្នាំអាចនឹងមិនសម្រេចបានតាមផែនការ, ផ្នែកចំណាយក៏អាចមានហានិភ័យ និងជួបបញ្ហាប្រឈមមួយចំនួនដូចបានជម្រាបជូនខាងលើ។ ក្នុងន័យនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានចាត់វិធានការដោះស្រាយចំពោះមុខ ដូចខាងក្រោម៖

៤.២.១-វិធានការអនុវត្តបន្តលើការប្រមូលចំណូល

ដើម្បីធានាសម្រេចបានការប្រមូលចំណូលដូចដែលបានរំពឹងទុក ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងបន្តយកចិត្តទុកដាក់អនុវត្តប្រកបដោយប្រសិទ្ធភាពខ្ពស់នូវវិធានការក្នុងយុទ្ធសាស្ត្រកៀរគរចំណូលឆ្នាំ ២០១៩-២០២៣ ដែលក្នុងនោះ៖

-ផ្នែកពន្ធដារ

- បន្តពង្រឹងការអនុវត្តកាតព្វកិច្ចដំឡើងឧបករណ៍វាស់ចំណុះស្រាបៀរ និងកេសដ្ឋ:គ្មានជាតិអាល់កុលរបស់សហគ្រាសផលិតក្នុងស្រុក (Flowmeter) ដើម្បីពង្រឹងប្រសិទ្ធភាពនៃការប្រមូលចំណូល និងធានាបាននូវការប្រកួតប្រជែងដោយស្មើភាពក្នុងវិស័យនេះ;
- បន្តពង្រឹងការចុះបញ្ជីពន្ធដារ និងការធ្វើបច្ចុប្បន្នភាពព័ត៌មានសហគ្រាស ព្រមទាំងបន្តតាមដានការបំពេញកាតព្វកិច្ចសារពើពន្ធរាល់សហគ្រាសដែលបានចុះបញ្ជីពន្ធដារដោយជោគជ័យ ក្នុងគោលដៅពង្រឹងការគ្រប់គ្រងប្រមូលចំណូលពន្ធ និងក្នុងគោលដៅកាត់បន្ថយហានិភ័យពាក់ព័ន្ធនានា;
- បន្តពង្រឹងការងារគ្រប់គ្រងការបង្វិលសងអាករលើតម្លៃបន្ថែម (VAT) ដោយបន្តយកចិត្តទុកដាក់ផ្ទៀងផ្ទាត់(Cross check) និងពិនិត្យបន្ថែមលើឥណទានអាករលើធាតុចូល និងវិក្កយបត្រសម្រាប់បង្វិលសងអាករលើតម្លៃបន្ថែម;
- ពង្រឹងការងារគ្រប់គ្រងនិងតាមដានលើការដាក់លិខិតប្រកាសពន្ធរបស់សហគ្រាស ដោយចាត់វិធានការភ្លាមៗចំពោះសហគ្រាសដែលមិនបានដាក់លិខិតប្រកាស;
- ត្រៀមរៀបចំវិបស្សនាពន្ធដារ (Tax Retreat) ស្តីពីការអនុវត្តផែនការយុទ្ធសាស្ត្រ និងផែនការប្រតិបត្តិ ២០១៩-២០២៣ របស់យុទ្ធសាស្ត្រកៀរគរចំណូល និងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់អគ្គនាយកដ្ឋានពន្ធដារ;
- បន្តផ្សព្វផ្សាយ និងពង្រឹងការអនុវត្តនូវកម្មវិធី វិក្កយបត្រនាំសំណាង ក្នុងគោលដៅពង្រឹងការអនុវត្តវិធានវិក្កយបត្រក្នុងចំណោមអ្នកជាប់ពន្ធតាមរយៈការចូលរួមរបស់សាធារណជនទូទៅ

- បន្តពង្រឹងការតាមដាន និងគ្រប់គ្រងប្រមូលចំណូលពន្ធលើវិស័យដែលមានសក្តានុពល ដើម្បីធានានូវប្រសិទ្ធភាព តម្លាភាព និងការប្រកួតប្រជែងដោយស្មើភាព ជាពិសេស វិស័យមួយចំនួនដែលអាចជាសក្តានុពលរួមមានវិស័យធនធានរ៉ែ វិស័យនាំចូល និងលក់យានយន្ត ជាដើម ដើម្បីឱ្យចូលខ្លួនមកចុះបញ្ជីពន្ធដារ និងអនុវត្តកាតព្វកិច្ចសារពើពន្ធឱ្យបានត្រឹមត្រូវ ស្របតាមច្បាប់ និងបទប្បញ្ញត្តិស្តីពីពន្ធដារ;
- សិក្សា និងរៀបចំវិធានការបំពាក់ឧបករណ៍កំណត់ទីតាំង GPS លើមធ្យោបាយដឹកជញ្ជូនរបស់សហគ្រាសក្នុងវិស័យសំខាន់ៗ ក្នុងគោលដៅគ្រប់គ្រងទិន្នន័យក្នុងការប្រកាសពន្ធ;
- ពង្រឹងការកត់ត្រាបំណុលពន្ធ អនុវត្តការប្រមូលបំណុលពន្ធ និងវិធានការតឹងទារបំណុលពន្ធ ជាពិសេសបំណុលពន្ធធំៗដែលមានសក្តានុពលដោយកំណត់ជាបំណុលអាទិភាព;
- បន្តរៀបចំយន្តការកំណត់អត្តសញ្ញាណអចលនទ្រព្យ (Property ID) ដើម្បីបញ្ជាក់ថាអចលនទ្រព្យនីមួយៗបានបង់ពន្ធរួចរាល់ចៀសវាងការលក់ដូរអចលនទ្រព្យមិនបានបង់ពន្ធ;
- ជំរុញការផ្តល់សេវាពន្ធលើអចលនទ្រព្យជូនសាធារណជន ដោយបង្កភាពងាយស្រួលតាមរយៈការរៀបចំក្តយបត្រពន្ធលើអចលនទ្រព្យ សម្រាប់អចលនទ្រព្យនីមួយៗ;
- បន្តពង្រឹងការគ្រប់គ្រងសហគ្រាសស្នើសុំផ្អាកបណ្តោះអាសន្ន ឬបិទស្ថាពរ ហើយស្នើសុំបើកដំណើរការឡើងវិញដោយមានវិធានការចុះពិនិត្យដល់ទីតាំងសហគ្រាសផ្ទាល់ តាមដានលើការដាក់លិខិតប្រកាស និងពង្រឹងការធ្វើសវនកម្មលើលិខិតស្នាម;
- បន្តពង្រឹង និងយកចិត្តទុកដាក់ចំពោះការស្នើសុំបិទសហគ្រាស និងការធ្វើសវនកម្មសម្រាប់សហគ្រាសស្នើសុំបិទ;
- បន្តពង្រឹងការផ្សព្វផ្សាយច្បាប់ និងបទប្បញ្ញត្តិស្តីពីពន្ធដារ កំណែទម្រង់ និងទំនើបកម្មរដ្ឋបាលសារពើពន្ធ និងបន្តពង្រឹងការផ្តល់សេវាជូនអ្នកជាប់ពន្ធ តាមរយៈការរៀបចំកម្មវិធីរៀនអំពីពន្ធដារតាមអនឡាញ (Tax Education) កិច្ចប្រជុំ សិក្ខាសាលា វិបស្សនា គេហទំព័រ ទំព័រទំនាក់ទំនងសង្គម និងការផ្សព្វផ្សាយផ្ទាល់តាមអនឡាញ ជាពិសេសការរៀបចំកម្មវិធី "ពន្ធដារកម្ពុជា" ដោយមានការជួបជជែកជាមួយអ្នកជាប់ពន្ធផ្ទាល់តាមប្រព័ន្ធបណ្តាញសង្គម GDT Facebook Live, សេវាឆ្លើយតបតាមប្រព័ន្ធទូរស័ព្ទ Call Center 1277, កម្មវិធី GDT Live Chat ជាដើម;
- បន្តអនុវត្តវិធានការចាំបាច់នានា ដូចមានកំណត់ក្នុងសារាចរណែនាំស្តីពីការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២២ និងបន្តអនុវត្តដោយយកចិត្តទុកដាក់នូវយុទ្ធសាស្ត្រកៀគរចំណូល ២០១៩-២០២៣។

-ផ្នែកចំណូលពន្ធអាករគយ

- បន្តវាយតម្លៃផលប៉ះពាល់លើចំណូលគយពីការលើកទឹកចិត្តវិនិយោគ, ការអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីនានា និងការកើនឡើងនូវផលិតកម្មក្នុងស្រុកជំនួសការនាំចូល, ព្រមទាំងការពិនិត្យលទ្ធភាពកែសម្រួលអត្រាពន្ធនិងអាករ លើមុខទំនិញនានា;
- ពង្រឹងបន្ថែមទៀតនូវអភិបាលកិច្ចល្អក្នុងស្ថាប័ន ប្រសិទ្ធភាពការងារបច្ចេកទេសគយ និងអនុលោមភាពផ្នែកឯកជន ដើម្បីទ្រទ្រង់ការប្រមូលចំណូល;

- បន្តធ្វើបច្ចុប្បន្នភាពជាប្រចាំនូវតារាងទិន្នន័យតម្លៃចម្លងការសម្រាប់ជាមូលដ្ឋានពិចារណាឱ្យបានស្របតាមការវិវត្តនៃទីផ្សារ, និងការវាយតម្លៃហានិភ័យលើធុរជននិងទំនិញ ក្នុងការងារផ្ទៀងផ្ទាត់តម្លៃគិតពន្ធគយ ចំណាត់ថ្នាក់ទំនិញ និងដើមកំណើតទំនិញ;
- បន្តការពិនិត្យលទ្ធភាពពង្រីកការធ្វើវិមជ្ឈការការងារផ្ទៀងផ្ទាត់តម្លៃគិតពន្ធគយ និងវិញ្ញាបនបត្រដើមកំណើតទំនិញ ទៅអង្គភាពគយនិងរដ្ឋាករមូលដ្ឋាន ដោយឈរលើមូលដ្ឋានកម្រិតអនុលោមភាពធុរជន និងគោលការណ៍គ្រប់គ្រងហានិភ័យ;
- លើកកម្ពស់ប្រសិទ្ធភាពការគ្រប់គ្រងការអនុវត្តអត្រាពន្ធអនុគ្រោះ ក្រោមក្របខ័ណ្ឌកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី និងការលើកទឹកចិត្តដាក់ពន្ធអាករបន្ទុករដ្ឋតាមបទប្បញ្ញត្តិជាធរមាន;
- បន្តជំរុញការអនុវត្តវិធានបញ្ជាក់ជាមុនលើចំណាត់ថ្នាក់ទំនិញ ដើមកំណើតទំនិញ និងតម្លៃគិតពន្ធគយ;
- បន្តធ្វើវិចារណកម្ម នៃមុខទំនិញមួយចំនួនដែលពុំមែនជាមុខសញ្ញានៃការលើកទឹកចិត្ត;
- ពង្រឹងយន្តការកិច្ចសម្រួលពាណិជ្ជកម្ម តាមរយៈការធ្វើសាមញ្ញកម្មនីតិវិធីគយ, កែលម្អប្រព័ន្ធស្វ័យប្រវត្តិកម្មគយ និងប្រតិបត្តិការគយ, ការលើកទឹកចិត្តដល់ធុរជនមានអនុលោមភាពខ្ពស់ និងជំរុញការអនុវត្តបញ្ញត្តិនៃកិច្ចព្រមព្រៀងស្តីពីកិច្ចសម្រួលពាណិជ្ជកម្មរបស់ WTO;
- បង្កើនប្រសិទ្ធភាពការងារបង្ការនិងបង្ក្រាបអំពើរត់គេចពន្ធ បន្លំពន្ធ និងបទល្មើសឆ្លងដែនដោយអនុវត្តយន្តការបង្ការ ទប់ស្កាត់ និងបង្ក្រាបបទល្មើសគយ;
- បន្តពង្រឹងយន្តការភាពជាដៃគូជាមួយវិស័យឯកជនក្នុងការពិគ្រោះយោបល់ និងដោះស្រាយបញ្ហានានា;
- ប្រឹងប្រែងកៀរគរចំណូលឱ្យអស់លទ្ធភាពតាមសក្តានុពលដែលនៅសេសសល់។

-ផ្នែកចំណូលមិនមែនសារពើពន្ធ

វិធានការពង្រឹងកៀរគរចំណូលមិនមែនសារពើពន្ធ មានដូចខាងក្រោម៖

- **ជំរុញការរៀបចំច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ៖** ច្បាប់នេះត្រូវបានចាត់ទុកជាច្បាប់គោលដំបូងគេ ដែលចែងអំពីប្រព័ន្ធគ្រប់គ្រងចំណូល ម.ព និងក្លាយជាឧបករណ៍គតិយុត្តិដ៏សំខាន់សម្រាប់ចូលរួមចំណែកពង្រឹងអភិបាលកិច្ចចំពោះការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធប្រកបដោយប្រសិទ្ធភាព និងចីរភាព។ ច្បាប់នេះ ត្រូវបានគ្រោងដាក់ឆ្លងស្ថាប័ននីតិប្បញ្ញត្តិ នាចុងឆ្នាំ ២០២២ នេះ;
- **ពង្រឹងកិច្ចសហការ៖** ពង្រឹងកិច្ចសហការជាមួយក្រសួងស្ថាប័នប្រមូលចំណូល ដើម្បីអនុវត្តអនុក្រឹត្យស្តីពីការគ្រប់គ្រងចំណូល ម.ព សំដៅពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រងការកត់ត្រា និងការផ្តល់របាយការណ៍ចំណូលមានតម្លាភាព និងទាន់ពេលវេលាជាមួយនឹងការទទួលខុសត្រូវ;
- **ជំរុញការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ NRMIS៖** បង្កើនប្រសិទ្ធភាពនៃការអនុវត្តប្រព័ន្ធ NRMIS នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងការ-ប្រើប្រាស់ប្រព័ន្ធទូទាត់អេឡិចត្រូនិច (E-Payment) ដើម្បីពង្រឹងប្រសិទ្ធភាពនៃការកត់ត្រា និងតាមដានការប្រមូលចំណូលមិនមែនសារពើពន្ធ;

- **ចំណូលពីការជួល៖** ករណីស្ថានភាពកូវីដ-១៩ ត្រូវបានធូរស្បើយ ការអនុវត្តរូបមន្តក្នុងការគណនាតម្លៃជួលថ្មីផ្អែកតាមតម្លៃគិតពន្ធប្រចាំប៉ុន្តាន់ត្រាផ្ទះអចលនទ្រព្យរបស់អគ្គនាយកដ្ឋានពន្ធដារ ដែលទទួលបានគោលការណ៍ឯកភាពដ៏ខ្ពង់ខ្ពស់ចុះថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០២០ ចំណូលនេះអាចនឹងកើនឡើងប្រមាណ ១០ ដង;
- **ចំណូលពីវិស័យរ៉ែ៖** មានវិធានការ និងចំណូលថ្មីៗមួយចំនួន ដូចខាងក្រោម៖
  - ចំណូលសួយសារពីវិស័យរ៉ែ នឹងកើនឡើងដោយផ្អែកលើអត្រាសួយសារដែលត្រូវបានកែសម្រួល តាមប្រកាសអន្តរក្រសួងលេខ ៧៦០ សហវ.ប្រក ចុះថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០២០ ស្តីពីអត្រាសួយសារលើតម្លៃផលិតផលរ៉ែ និងនីតិវិធីនៃការបង់ថ្លៃសួយសារ;
  - ចំណូលពីសួយសារខ្សាច់នាំចេញក្រៅប្រទេសដែលជាចំណូលថ្មី (ចំនួន ២ ក្រុមហ៊ុន) ដោយអនុវត្តពីចុងឆ្នាំ ២០២០ មកដល់បច្ចុប្បន្ន ដោយគិតត្រឹមថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០២២, ចំណូលនៃមុខសញ្ញានេះទទួលបានចំនួន ២ ៤២៧ ២៥២ ដុល្លារអាម៉េរិក;
  - ចំណូលពីសួយសាររ៉ែមាសរបស់ក្រុមហ៊ុន Renaissance Minerals Cambodia Limited នៅខេត្តមណ្ឌលគិរី ដែលបានដំណើរការពីថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០២១ ដោយគិតត្រឹមថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០២២, ក្រុមហ៊ុនចម្រាញ់ផលិតមាសបានចំនួន ២០៦ ដុំ ស្មើនឹង ៣ ០៩០,២០ គក្រ. ដែលសួយសារគ្រោងទទួលបានប្រមាណ ៤ ៦៣៥ ៣០០ ដុល្លារអាម៉េរិក (៥០ ០០០ ដុល្លារអាម៉េរិក x ៣ ០៩០,២០ គក x ៣% សួយសារ);
  - បន្តពង្រឹងប្រសិទ្ធភាពនៃការប្រមូលចំណូលពីវិស័យរ៉ែ ដោយធ្វើការចុះផ្ទៀងផ្ទាត់ការបង់សួយសារជាមួយបរិមាណធ្វើអាជីវកម្មជាក់ស្តែងរបស់ក្រុមការងារអន្តរក្រសួង;
  - គ្រោងធ្វើការកែសម្រួលប្រកាសអន្តរក្រសួងលេខ ៦៦៤ សហវ.ប្រក ស្តីពីការកំណត់ថ្លៃឈ្នួលដីតំបន់អាជ្ញាបណ្ណធនធានរ៉ែ;
  - ជំរុញចាត់វិធានការតឹងទារបំណុលពីវិស័យរ៉ែដែលនៅសេសសល់។
- **ចំណូលពីប្រាក់ចំណេញសហគ្រាស៖** រំពឹងថាសហគ្រាសសាធារណៈមួយចំនួននឹងបង់ភាគលាភបន្ថែម មានដូចជា កំពង់ផែស្វយ័តក្រុងព្រះសីហនុ, រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ, និងគ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ;
- **វិធានការថ្មីបន្ថែម៖** ដើម្បីពង្រឹងចំណូល ម.ព បន្ថែមទៀត ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានលើកវិធានការថ្មីៗ ដូចខាងក្រោម៖
  - ជំរុញតឹងទារបំណុលក្នុងវិស័យទូរគមនាគមន៍ពីប្រតិបត្តិករដែលមិនទាន់មានអនុលោមភាពល្អ;
  - ដកហូតមកវិញនូវប្រេកង់ដែលមិនប្រើប្រាស់ ដើម្បីដាក់ដេញថ្លៃឡើងវិញ និងទទួលបានប្រភពចំណូលបន្ថែមខ្លះ;
  - ជំរុញការអនុវត្តសេចក្តីជូនដំណឹងលេខ ៨១១ សជណ.ហធ ចុះថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០១៩ ដែលទទួលបានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់របស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** រួចហើយ លើគោលការណ៍គណនាថ្លៃឈ្នួលសម្បទានដីសេដ្ឋកិច្ចឡើងវិញ;

- ជំរុញ និងពង្រឹងការគ្រប់គ្រងការប្រមូលចំណូលពីសម្បទានដីសេដ្ឋកិច្ច និងធនធានរ៉ែ តាមរយៈប្រព័ន្ធបង់ប្រាក់អេឡិចត្រូនិក, បង់ប្រាក់រំដោះឱ្យទៀងទាត់ ដោយមានការធ្វើអធិការកិច្ចចំពោះអាជីវករ/ក្រុមហ៊ុន និងពិនិត្យផ្ទាល់ដល់ទីតាំង ឬការដ្ឋានអាជីវកម្ម ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីធ្វើងផ្ទាត់ការបង់ចំណូល ព្រមទាំងពង្រឹងយន្តការប្រមូលចំណូល និងកិច្ចសហប្រតិបត្តិការរវាងក្រសួងទទួលបន្ទុក ដើម្បីធានាឱ្យអាជីវករ/ក្រុមហ៊ុនធ្វើអាជីវកម្ម បង់ចំណូលបានគ្រប់ចំនួន និងទាន់ពេលវេលា។

៤.២.២-វិធានការដោះស្រាយលើការអនុវត្តចំណាយ

ផ្អែកតាមការវាយតម្លៃស្ថានភាពម៉ាក្រូសេដ្ឋកិច្ច និងភាពប្រសើរឡើងវិញខ្លះនៃការប្រមូលចំណូលសារពើពន្ធនៅឆមាសទី ១ និងដើម្បីធានាការអនុវត្តច្បាប់ថវិកាឆ្នាំ ២០២២ ឱ្យមានប្រសិទ្ធភាព ក្នុងគោលដៅជំរុញកំណើនសេដ្ឋកិច្ចជាតិ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានដាក់ចេញនូវវិធានការផ្អែកចំណាយ ដូចខាងក្រោម៖

- អនុញ្ញាតផ្តល់ធានាចំណាយថវិកាចរន្ត ៥០% ដំហានទី ២ លើមុខសញ្ញាចំណាយកិច្ចលទ្ធកម្ម ដែលមានទំហំឥណទានធំជាង ១ ០០០ លានរៀល ហើយអនុវត្តដោយបន្តកិច្ចសន្យាឆមាសទី ១ តែម្តង,
- អនុញ្ញាតផ្តល់ធានាចំណាយថវិកាមូលធន ៥០% ដំហានទី ២ សម្រាប់គម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវន្តរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន, ក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងធនធានទឹក និងឧតុនិយម,
- អនុញ្ញាតផ្តល់ថវិកាដំហាន ២ សម្រាប់គម្រោងសាច់ប្រាក់ពលកម្ម ដោយផ្តល់អាទិភាពលើផ្នែកប្រព័ន្ធស្រោចស្រព ដើម្បីបង្កើនផលិតកម្មផ្នែកចំណីអាហារ និង សុវត្ថិភាពស្បៀង
- បន្តពិនិត្យកែសម្រួលនីតិវិធីបន្ថែមតាមការចាំបាច់ ដើម្បីផ្តល់កិច្ចសម្រួលខាងនីតិវិធីផង ព្រមទាំងដើម្បីលើកកម្ពស់ប្រសិទ្ធភាព និងការទទួលខុសត្រូវក្នុងការអនុវត្តថវិកាផងដែរ ដោយមិនបោះបង់ចោលគោលដៅនៃការបង្កើនប្រសិទ្ធភាពចំណាយនោះទេ ពោលគឺ "**មិនអនុញ្ញាតឱ្យចាយខ្ជះខ្ជាយ ដើម្បីឱ្យអស់ឥណទានថវិកាដែលមានក្នុងច្បាប់ ដោយមិនគិតពីប្រសិទ្ធភាពនិងគុណភាពនៃចំណាយនោះទេ**"។
- បន្តពង្រឹងប្រសិទ្ធភាពប្រតិបត្តិការចំណាយដោយតម្រង់ការចាយឱ្យចំមុខសញ្ញាចំណាយ និងចាយតែលើមុខសញ្ញាចំណាយដែលចាំបាច់ខ្លាំង ទន្ទឹមគ្នានឹងការតែបន្ត្រឹងបន្ថែមទៅលើមុខសញ្ញាចំណាយដែលលែងចាំបាច់ ឬមិនសូវចាំបាច់ ដើម្បីបង្វែរឥណទានថវិកាទាំងនោះទៅដោះស្រាយការងារអាទិភាពចំពោះមុខរបស់រាជរដ្ឋាភិបាល;
- តែត្បិតការចាយរបស់ក្រសួង-ស្ថាប័ន មិនឱ្យលើសពីទំហំកញ្ចប់ឥណទានថវិកាដែលមានក្នុងច្បាប់ថវិកាឆ្នាំ ២០២២, ទន្ទឹមគ្នានឹងការបង្កើននូវការធានា "តម្លៃនៃលុយ", ដែលរួមទាំងមុខចំណាយប្រេងឥន្ធនៈ, អង្ករ និងប្រាក់បេសកកម្ម ជាដើម;
- ជំរុញការអនុវត្តចំណាយទាំងផ្នែកចំណាយចរន្ត និងចំណាយវិនិយោគដោយថវិកាជាតិ តាមរយៈការដាក់ជាវិធានការក្នុងការតាមដានវឌ្ឍនភាព ទាំងការអនុវត្តការងារជាប្រចាំ ការអនុវត្តនីតិវិធី

លទ្ធកម្ម និងនីតិវិធីហិរញ្ញវត្ថុជាធរមាន ដើម្បីធានាការទូទាត់ថវិកាបានទាន់ពេលវេលានៅដំណាច់ឆ្នាំ ២០២២ ស្របតាមគោលដៅកំណត់ដោយច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០២២;

- បន្តពង្រឹងអង្គភាពថវិកានៃក្រសួង-ស្ថាប័នលើទទួលខុសត្រូវក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍សមិទ្ធកម្មឱ្យបានត្រឹមត្រូវ និងទាន់ពេលវេលាទៅតាមគោលការណ៍ណែនាំស្តីពីនីតិវិធីអនុវត្តថវិកាកម្មវិធី និងសាកចរណែនាំស្តីពីការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ;
- បន្តជំរុញក្រសួង-ស្ថាប័នក្នុងការកែលម្អចំណុចខ្វះចន្លោះនៅក្នុងដំណើរការគ្រប់គ្រង និងប្រតិបត្តិការរបស់ខ្លួន ពាក់ព័ន្ធនឹងភាពត្រឹមត្រូវ អនុលោមភាព និងប្រសិទ្ធភាព ដែលផ្តល់ជូនដោយសមត្ថកិច្ចខាងសវនកម្ម និងអធិការកិច្ចហិរញ្ញវត្ថុ។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងប្រើ-ប្រាស់លទ្ធផលកែលម្អតាមអនុសាសន៍សវនកម្ម និងវិធានការរបស់អធិការកិច្ចហិរញ្ញវត្ថុ រួមជាមួយលទ្ធផលនៃការខិតខំប្រឹងប្រែងអនុវត្តតាមការកំណត់មួយចំនួនទៀតរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាបុរេលក្ខណៈវិនិច្ឆ័យបន្ថែម សម្រាប់ផ្តល់ការលើកទឹកចិត្តជូនក្រសួង-ស្ថាប័ននៅក្នុងការចរចាថវិកា;
- បន្តការគាំទ្រ និងជំរុញការអនុវត្តផែនការសកម្មដែលត្រូវបានកែសម្រួល និងធ្វើបច្ចុប្បន្នកម្ម ក្នុងឆ្នាំ ២០២២ នៃយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ ២០១៨-២០២៥ និងយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ ២០១៩-២០២៥ ព្រមទាំងយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈឆ្នាំ ២០១៩-២០២៥;
- បន្តពង្រឹងការធ្វើអធិការកិច្ចហិរញ្ញវត្ថុ និងសវនកម្ម និងលើកកម្ពស់ការចាត់វិធានការរដ្ឋបាល និងវិន័យហិរញ្ញវត្ថុតាមច្បាប់ជាធរមានលើការអនុវត្តថវិកា

ជារួម តាមរយៈការដាក់ចេញវិធានការចាំបាច់នានាខាងលើ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងខិតខំធានាឱ្យបានទាំងគោលដៅនៃការជំរុញល្បឿននៃការអនុវត្តចំណាយតាមច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០២២ ព្រមទាំងគោលដៅនៃការលើកកម្ពស់ប្រសិទ្ធភាពនិងស័ក្តិសិទ្ធិភាពនៃចំណាយ ទាំងក្នុងកម្រិតបច្ចេកទេស និងប្រតិបត្តិការស្របតាមនីតិវិធីហិរញ្ញវត្ថុសាធារណៈជាធរមាន។

៥-សេចក្តីសន្និដ្ឋាន

ផ្អែកតាមការវាយតម្លៃពាក់កណ្តាលឆ្នាំ ២០២២ សេដ្ឋកិច្ចកម្ពុជាត្រូវបានប៉ាន់ស្មានថានឹងមានកំណើន ៥,៤% គឺខ្ពស់ជាងការព្យាករក្នុងអត្រា ៤,៨ % នៅពេលរៀបចំច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២២ ក៏ប៉ុន្តែ ទាបជាងការព្យាករកាលពីដើមឆ្នាំដែលត្រូវបានប៉ាន់ស្មានថាមានកំណើនក្នុងអត្រា ៥,៦% ដោយសារផលប៉ះពាល់ពីជំងឺកូវីដ-១៩ មិនទាន់ប្រសើរឡើងទាំងស្រុង ហើយសង្គ្រាមរវាងរុស្សុី និងអ៊ុយក្រែន ក៏កំពុងបង្កើតឡើងនូវផលប៉ះពាល់បន្តបន្ទាប់ ជាពិសេសគឺបញ្ហាអតិផរណាលើថ្លៃប្រេង ស្បៀង និងម្ហូបអាហារ។ ហានិភ័យពីកត្តាខាងក្រៅប្រទេស និងក្នុងប្រទេស ទាមទារឱ្យរាជរដ្ឋាភិបាលត្រូវត្រៀមលក្ខណៈរួចជាស្រេចក្នុងការបញ្ចៀស និងបន្ធូរបន្ថយសម្ពាធហានិភ័យ និងបញ្ហាប្រឈមនានា ដែលនឹងអាចកើតឡើងជាយថាហេតុ តាមរយៈការដាក់ចេញ និងអនុវត្តវិធានការគោលនយោបាយដែលឆ្លើយតបទាំងក្នុងផ្នែកម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ។ ក្នុងន័យនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងបន្តតាមដាន និងវាយតម្លៃជាប់ជាប្រចាំ

ប្រកបដោយការយកចិត្តទុកដាក់ខ្ពស់ និងត្រៀមលក្ខណៈក្នុងការដាក់ចេញវិធានការអន្តរាគមន៍ ឆ្លើយតបឱ្យបានទាន់ពេលវេលាលើបញ្ហានានាដែលអាចកើតមានជាយថាហេតុ។

ទោះបីការអនុវត្តថវិកាក្នុងធមាសទី ១ កន្លងទៅនេះ នៅជួបប្រទះបញ្ហាប្រឈមមួយចំនួនក្តី ក៏ប៉ុន្តែដោយមានការគាំទ្រ និងការលើកទឹកចិត្តយ៉ាងពេញទំហឹង និងជាប្រចាំពី **សម្តេចតេជោនាយករដ្ឋមន្ត្រី** ដែលជាមេបញ្ជាការតែមួយ និងស្មារតីនៃការបន្តចូលរួមយ៉ាងសកម្មពីគ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុប្តេជ្ញាចិត្តដោយមិនរាថយក្នុងការពុះពារសម្រេចឱ្យបាននូវគោលដៅ និងវិធានការទាំងឡាយដែលបានលើកឡើងខាងលើ។

ដូចនេះ ថវិកាឆ្នាំ ២០២២ នៅតែអាចចាត់ទុកថាជាឧបករណ៍គោលនយោបាយរបស់រាជរដ្ឋាភិបាលប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព ក្នុងការការពារ និងការការពារសេដ្ឋកិច្ច និងជីវភាពប្រជាជន ទប់ទល់នឹងផលប៉ះពាល់ពីជំងឺកូវីដ-១៩ ព្រមទាំងបម្រើដល់ការស្តារសេដ្ឋកិច្ច និងជំរុញកំណើនជាបណ្តើរៗឡើងវិញ។ ជាមួយគ្នានេះ ថវិកាឆ្នាំ ២០២២ ក៏បានគូសបញ្ជាក់អំពីការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាល ក្នុងការខិតខំបង្កើនប្រសិទ្ធភាព និងកម្រិតនៃការកៀរគរចំណូលគ្រប់ប្រភេទ តាមរយៈការអនុវត្តវិធានការយ៉ាងម៉ឹងម៉ាត់និងមុតស្រួចទាំងវិធានការរដ្ឋបាល និងវិធានការគោលនយោបាយ ដែលមានចែងនៅក្នុងយុទ្ធសាស្ត្រកៀរគរចំណូលឆ្នាំ ២០១៩-២០២៣ ទន្ទឹមនឹងការបន្តគោលនយោបាយបន្ធូរបន្ថយ និងអនុគ្រោះពន្ធ ដើម្បីទ្រទ្រង់ដំណើរការអាជីវកម្ម ដែលប៉ះពាល់ដោយសារការអូសបន្លាយនៃស្ថានភាពរីករាលដាលនៃជំងឺកូវីដ-១៩។

***** ចប់ *****